គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី

**NIRON MICROFINANCE PLC.**

# របាយការណ៍ប្រចាំឆ្នាំ
# ២០២០

# មាតិកា


| | |
|---|---|
| ប្រវត្តិសំខាន់ៗ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ៍ អ៊ីអិលស៊ី | ០១ |
| បណ្ដាញការិយាល័យប្រតិបត្តិការ | ០៤ |
| ទស្សនវិស័យ និងបេសកកម្ម | ០៥ |
| លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ | ០៦ |
| លទ្ធផលសង្ខេបផ្នែកប្រតិបត្តិការ | ០៧ |
| សូចនាករសេដ្ឋកិច្ចសំខាន់ៗរបស់ប្រទេសកម្ពុជា | ០៨ |
| ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក | ០៩ |
| រចនាសម្ព័ន្ធគ្រប់គ្រង | ១១ |
| សមាសភាពក្រុមប្រឹក្សាភិបាល | ១២ |
| សមាសភាពគណៈគ្រប់គ្រង | ១៤ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១៧ |
| របាយការណ៍របស់សវនករឯករាជ្យ | ២២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ២៦ |
| របាយការណ៍លទ្ធផលលម្អិត | ២៧ |
| របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន | ២៨ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៣០ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ៣២ |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរ្គរ ភីអិលស៊ី

## សូមស្វាគមន៍


ការិយាល័យកណ្តាល

អគារលេខៈ ២១-២៣-២៥, ផ្លូវលេខ៥៩៨, សង្កាត់ភ្នំពេញថ្មី, ខណ្ឌ សែនសុខ,

រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា,

ទូរស័ព្ទលេខៈ០៨៦ ៦៥៥ ៩៩៩,

អ៊ីម៉េល : info@niron.com.kh វេបសាយ : www.niron.com.kh






# អំពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី** គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មជាផ្លូវការនៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៤ ពីសំណាក់ធនាគារជាតិនៃកម្ពុជា។ ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី មានការិយាល័យចំនួន ១១ នៅតាមបណ្តាស្រុក-ខេត្ត-ក្រុង-រាជធានី (ការិយាល័យកណ្តាល ០១ និងសាខាចំនួន ១០) និងមានបុគ្គលិកសរុប ២០០នាក់។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី មានអតិថិជនសកម្មចំនួន ៥.៣៩៨នាក់ និងទំហំឥណទានដុលសរុបចំនួនជាង ១,៥៤ លានដុល្លារអាមេរិក ជាមួយនឹងកម្រិតឥណទានមានហានិភ័យ (PAR) ទាប។

សាខារបស់គ្រឹះស្ថាន

១១ សាខាទូទាំងប្រទេស

បុគ្គលិកបម្រើការងារចំនួន

២០០ នាក់

អតិថិជនខ្ចីប្រាក់ចំនួន

៥.៣៩៨ នាក់

ទំហំឥណទានដុលសរុប

ប្រមាណ១,៥៤ លានដុល្លារអាមេរិច

# ការវិវឌ្ឍន៍របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី

## ២០០៨

បង្កើត និងដំណើរការដំបូងជា អង្គការហិរញ្ញវត្ថុ
“និរន្តទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចសហគន៍”

នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨

## ២០០៩

ចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាល ដោយ
អនុលោមតាមច្បាប់សមាគមន៏ និងច្បាប់ការងារ
ដែលទទួលស្គាល់ដោយក្រសួងមហាផ្ទៃ

## ២០១៣

និរន្តទីភ្នាក់ងារអភិវឌ្ឍន៏សេដ្ឋកិច្ចសហគមន៏បាន
វិវត្តន៏ខ្លួនជានិរន្តរគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភីអិលស៊ី
ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត
ដែលទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា

## ២០១៥

ច្របាច់ចូលគ្នាជាមួយអង្គការក្រៅ រដ្ឋាភិបាល
ក្នុងស្រុកមួយរួចប្តូរនាមករណ៏ជា គ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី

## ២០១៦

គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និរន្តរភីអិលស៊ី មាន

បណ្តាញប្រតិបត្តិការចំនួន ៥៥ សាខាគ្របដណ្តប់
លើ ២៤ខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
ជាមួយបុគ្គលិកបម្រើការងារ ១០១៨នាក់

## ២០១៨

សាខាមួយចំនួនត្រូវបានបិទ ដើម្បីកាត់បន្ថយ
បណ្តាញប្រតិបត្តិការដែលមិនមានសក្តានុពល
និងដើម្បីធានាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការ
ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន

## ២០១៩

ក្នុងឆ្នាំនេះប្រតិបត្តិការ បណ្តាលសាខារបស់គ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ និរន្តរ បានកើនឡើង បើធៀបនិង
ផែនការដែលដាក់ចេញ, លទ្ធភាពក្នុងការស្វែងរក
ប្រាក់ចំណេញបានមានភាពល្អប្រសើរជាងមុន

## ២០២០

ក្នុងស្ថានភាពដែលសេដ្ឋកិច្ចក្នុងប្រទេស រងផល
ប៉ះពាល់ពីការរីករាលដាលនៃជំងឺ កូវីដ-១៩
គ្រឹះស្ថាន បានដាក់ចេញនូវវិធានការ និង
យុទ្ធសាស្រ្តផ្សេងៗ ដើម្បីដំណើរការសកម្មភាព
ក្នុងស្ថានភាពនេះ។




# តំបន់ប្រតិបត្តិការរបស់ និរន្តរ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០,និរន្តរ មានបណ្តាញការិយាល័យទូទាំងប្រទេសដូចខាងក្រោម៖

| ល.រ | ការិយាល័យ/សាខា | អក្សរឡាតាំង |
|---|---|---|
| ១ | ការិយាល័យកណ្តាល | អគារលេខ ២១, ២៣, ២៥ ផ្លូវ ៥៥៨ សង្កាត់ភ្នំពេញថ្មី, ខណ្ឌសែនសុខ, រាជធានីភ្នំពេញ |
| ២ | សាខាក្រុងព្រះសីហនុ | ផ្ទះលេខ៣២២, ផ្លូវអូរ១, ភូមិលេខ៥, ឃុំលេខ៤, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ |
| ៣ | សាខាស្រុកព្រៃនប់ | ភូមិសំរុងក្រោម, ឃុំសំរុង, ស្រុកព្រៃនប់, ខេត្តព្រះសីហនុ |
| ៤ | សាខាស្រុកស្រែអំបិល | ភូមិត្រពាំង, ឃុំស្រែអំបិល, ស្រុកស្រែអំបិល, ខេត្តកោះកុង |
| ៥ | សាខាស្រុកបុទុមសាគរ | ភូមិថ្មស, ឃុំថ្មស, ស្រុកបុទុមសាគរ, ខេត្តកោះកុង |
| ៦ | សាខាស្រុកខ្សាច់កណ្តាល | ភូមិក្នុង, ឃុំព្រែកតាមាក់, ស្រុកខ្សាច់កណ្តាល, ខេត្តកណ្តាល |
| ៧ | សាខាស្រុកស្រីសន្ធរ | ភូមិសន្លែ, ឃុំព្រែកពោធិ៍, ស្រុកស្រីសន្ធរ, ខេត្តកំពង់ចាម |
| ៨ | សាខាខេត្តកំពង់ស្ពឺ | ផ្លូវជាតិលេខ៤, ភូមិមុខខេត្ត, សង្កាត់រកាធំ, ក្រុងច្បារមន, ខេត្តកំពង់ស្ពឺ |
| ៩ | សាខាក្រុងសៀមរាប | ផ្លូវកូម៉ៃ, ភូមិត្រពាំងសេះ, ឃុំគោកចក, ក្រុងសៀមរាប, ខេត្តសៀមរាប |
| ១០ | សាខាស្រុកអន្លង់វែង | ផ្លូវលេខ៦៧, ភូមិថ្នល់កែង, ឃុំអន្លង់វែង, ស្រុកអន្លង់វែង, ខេត្តឧត្តរមានជ័យ |
| ១១ | សាខាស្រុកសូទ្រនិគម | ភូមិដូនហុង, ឃុំដំដែក, ស្រុកសូទ្រនិគម, ខេត្តសៀមរាប |



# ទស្សនវិស័យ និង បេសកកម្ម

## ទស្សនវិស័យ

“គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី នឹងក្លាយជាគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ប្រកបដោយការអភិវឌ្ឍ និងគុណធម៌”។

## បេសកកម្ម

“គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី គឺជាគ្រឹះស្ថានដែលផ្តល់សេវាហិរញ្ញវត្ថុដ៏សំបូរបែបដល់ប្រជាពលរដ្ឋដោយផ្តោតជាអាទិភាពលើៈ ផ្តល់ភាពងាយស្រួលដល់អតិថិជន ក្នុងការទំនាក់ទំនងប្រើប្រាស់ សេវាហិរញ្ញវត្ថុ, បង្កើនភាពស្និទ្ធស្នាលនិងជាដៃគូដ៏ល្អ ដើម្បីឈានទៅរកភាពរីកចម្រើនទាំងអស់គ្នា, កសាងសមត្ថភាពបុគ្គលិក ពង្រីកបណ្តាញប្រតិបត្តិការអោយបានធំទូលាយ រួមជាមួយនឹងការអភិវឌ្ឍផលិតផល និងបច្ចេកវិទ្យាទំនើបទាន់សម័យ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ សីលធម៌ បរិស្ថាន និងកិច្ចការសង្គម”។

# លទ្ធផលសង្ខេបហិរញ្ញវត្ថុ




១.ទ្រព្យសកម្ម គិតជាពាន់រៀល




២.បំណុលគិតជាពាន់រៀល




៣.មូលនិធិទ្រព្យម្ចាស់ គិតជាពាន់រៀល




៤.ឥណទានដុល គិតជាពាន់រៀល




៥.ដើមទុន គិតជាពាន់រៀល




៦.ចំណូលដុល គិតជាពាន់រៀល




៧.ចំណេញមុនពេលដកពន្ធ គិតជាពាន់រៀល




៨.ចំណេញសុទ្ធក្រោយដកពន្ធ គិតជាពាន់រៀល



# លទ្ធផលសង្ខេបផ្នែកប្រតិបត្តិការ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ |
|---|---|
| ចំនួនការិយាល័យសរុប | ១១ |
| ចំនួនបុគ្គលិកសរុប | ២០០ |
| ប្រុស | ១៦១ |
| ស្រី | ៣៩ |
| មន្ត្រីឥណទាន ធៀបនឹងបុគ្គលិកសរុប | ៤០,៥០% |
| ចំនួនអតិថិជនសរុប | ៥.៣៩៨ |
| ទំហំឥណទានដុលសរុប (ដុល្លារអាមេរិក) | ១.៥៤៣.៤២៣ |
| ទំហំឥណទានដុល ធៀបនឹងមធ្យមភាគមន្ត្រីឥណទាន | ៦៧ |
| ទំហំឥណទានដុល ធៀបនឹងមធ្យមភាគមន្ត្រីឥណទាន (ដុល្លារអាមេរិក) | ១៩.០៥៥ |
| ទំហំឥណទានដុល ធៀបនឹងមធ្យមភាគអតិថិជន (ដុល្លារអាមេរិក) | ២៨៦ |

# សូចនាករសេដ្ឋកិច្ចសំខាន់ៗក្នុងប្រទេសកម្ពុជា

| | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០e | ២០២១f |
|---|---|---|---|---|---|---|---|
| **១ ផលិតផលសរុបក្នុងស្រុក .(GDP)** | | | | | | | |
| | បម្រែបម្រួលផលិតផលសរុបក្នុងស្រុក (%) | ៧ | ៧ | ៧,៥ | ៧,១ | -១,៩ | ៣,៥ |
| | ចំណូលក្នុង ១ នាក់ (គិតជាដុល្លារអាមេរិក) | ១.៣០២ | ១.៤២៧ | ១.៥៦៣ | ១.៧០០ | ១.៦៨៣ | ១.៧៧១ |
| **២អតិផរណា .** | | | | | | | |
| | អតិផរណា (មធ្យមប្រចាំឆ្នាំ) | ៣ | ២,៩ | ២,៥ | ១,៩ | ២,៩ | ៣,១ |
| | អតិផរណា (ចុងឆ្នាំ) | ៣,៩ | ២,២ | ១,៦ | ៣,១ | ២,៩ | - |
| **៣ ថវិការបស់រាជរដ្ឋាភិបាល .(គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក)** | | | | | | | |
| | ចំណូល | ១៨,៩ | ២០,២ | ២២,៣ | ២៥,៣ | ២៣,៨ | ១៨,២ |
| | ចំណាយ | ២២ | ២៣,៥ | ២៤,៦ | ២៦,១ | ៣០,១ | ២៧,១ |
| **៤ រូបិយប័ណ្ណ និងឥណទាន .(បម្រែបម្រួលជាភាគរយក្នុង ១២ខែ)** | | | | | | | |
| | រូបិយប័ណ្ណ (M2) | ២១ | ២៣,១ | ២៦,៦ | ១៨,២ | ១៥,៣ | - |
| | ប្រាក់បញ្ញើសរុបនៅក្នុងប្រព័ន្ធធនាគារ | ២១,៨ | ២៥,១ | ២៥,១ | ១៥,១ | ១៨ | - |
| | ឥណទានសរុបនៅក្នុងប្រព័ន្ធធនាគារ | ២០,៥ | ១៧,២ | ២៤,៣ | ២៣,៩ | ២៣,៤ | - |
| | ឥណទានធៀបនឹងប្រាក់បញ្ញើ (គិតជាភាគរយ) | ១០០,៦ | ៩៥,៣ | ៩២,២ | ៩៩ | ១០៣,៥ | - |
| | ឥណទានវិស័យឯកជន | ២២,៥ | ១៨,៥ | ២០,១ | ២៦,៣ | - | - |
| | ប្រាក់បញ្ញើធៀបនឹងផលិតផលសរុបក្នុងស្រុក | ៦៨,៤ | ៨៥,៦ | ៩១,១ | ៩៣,៣ | ១១០,២ | - |
| | ឥណទានធៀបនឹងផលិតផលសរុបក្នុងស្រុក | ៦៨,៨ | ៨០,៧ | ៨៣,៥ | ៩២ | ១១៤ | - |
| **៥ ជញ្ជីងទូទាត់ .(គិតជាលានដុល្លារអាមេរិក)** | | | | | | | |
| | ការនាំចេញ | ៩.៥៩៥ | ១០.៧៧៧ | ១១.២១៤ | ១៤.៥៣០ | ១៦.០០០ | - |
| | ការនាំចូល | ១២.០៧០ | ១៣.០១៩ | ១៣.៧៧១ | ២២.១៩០ | ១៦.០០០ | - |
| | ជញ្ជីងពាណិជ្ជកម្ម | (២.៤៧៥) | (២.២៤២) | (២.៥៥៧) | (៧.៦៦០) | - | - |
| | គណនីចរន្ត (មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ) | (២.៣១២,៥) | (២.១៤០,៥) | (២.១៨០,១) | (២.៧០៣,៩) | (២.៧០៣,៩) | (៣.៨១៤,១) |
| | ផលិតផលសរុបក្នុងស្រុកជាមធ្យម | ១៩,៨៦ | ២២,១៦ | ២៤,៦១ | ២៧,១៣ | ២៧,២២ | ២៩,០១ |
| | អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារ នៅចុងគ្រា) | ៤.០៥៦ | ៤.០៤៥ | ៤.០៣៧ | ៤.០៥៤ | ៤.០៦៥ | ៤.០៦៥ |



## លោក ឈុន ស្រ៊ា | ប្រធានក្រុមប្រឹក្សាភិបាល

# ចំណាប់អារម្មណ៍ របស់ ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២០ ទើបតែកន្លងផុតទៅថ្មីៗគឺ ជាឆ្នាំដែលសេដ្ឋកិច្ចនៅលើពិភពលោកកំពុងតែរងផលប៉ះពាល់ យ៉ាងខ្លាំងពីការរីករាលដាលនៃជំងឺកូវីដ-19 រួមទាំងប្រទេសកម្ពុជាផងដែរ។ កត្តាទាំងនេះធ្វើអោយអតិថិជនមួយចំនួន ទទួលរងនូវផលប៉ះពាល់ដល់ប្រភពចំណូល តាមការណែនាំរបស់ ធនាគារជាតិនៃកម្ពុជា តម្រូវអោយគ្រឹះស្ថានធ្វើ Restructure loan ជូនដល់អតិថិជនដែលមានបញ្ហា។ ទោះបីជាជំងឺ កូវីដ-19 បានបង្ករការគំរាមកំហែងដល់កំណើន សេដ្ឋកិច្ចក្តីក៏ គ្រិះស្ថានមីក្រូហិរញ្ញវត្ថុ និរន្ត ភីអិស៊ី បានធ្វើការចាត់វិធានការដោះស្រាយឆ្លើយតមទៅនឹងស្ថានភាពទាំងនេះ បានទាន់ពេលវេលា និងមានប្រសិទ្ធ ដោយសម្រេចបាននៅលទ្ធផលក្នុងឆ្នាំ ២០២០ មានដូចខាងក្រោម៖

- ROE សម្រេចបានត្រឹម : ៥,៥៩%
- ROA សម្រេចបានត្រឹម : ៥,២៩%
- Loan Outstanding សម្រេចបានត្រឹម : ១.៥៤៣.៤២៣ ដុល្លារអាមេរិក

ទោះបីជាឆ្នាំ២០២០ កន្លងមកនេះ យើងពុំអាចអនុវត្តតាមផែនការដែលបានកំណត់ ១០០% ក៏ពិតមែន ប៉ុន្តែលទ្ធផលហិរញ្ញវត្ថុយើងបានបង្ហាញពីភាពសមស្របនៃយុទ្ធសាស្រ្ត ភាពទាក់ទាញនៃផលិតផល និងការផ្តល់សេវាកម្មរបស់យើងព្រមទាំងកិច្ចខិតខំប្រឹងប្រែងធ្វើការ និងការសហការនៅក្នុងក្រុមការងាររបស់គ្រឹះស្ថានផងដែរ។

# គោលដៅហិរញ្ញវត្ថុ

Net Income
៤២២.៦០០
ដុល្លារអាមេរិច

Loan Outstanding
១.៨១០.០០០
ដុល្លារអាមេរិច

NPL Ratio
៣,៨៥%

WO.Collection
៣២.២០០
ដុល្លារអាមេរិច

## យុទ្ធសាស្ត្រគន្លឹះ

០១ បង្វែរគោលដៅយុទ្ធសាស្ត្រពីបរិមាណឥណទានមកជាប្រាក់ ចំណេញ

០២ ជំរុញយុទ្ធសាស្ត្រស្វែងរកប្រាក់ចំណេញតាមរយៈ ការលើក ទឹកចិត្តដល់ប្រតិបត្តិការ

០៣ ជំរុញការប្រមូលបំណុលលុបចេញពីបញ្ជីឱ្យអស់ពីលទ្ធភាព

០៤ បន្តពង្រឹង និងកែលម្អការងាររបស់នាយកដ្ឋានឥណទានដែលជានាយកដ្ឋានស្នូលរបស់គ្រឹះស្ថាន

០៥ បន្តស្វែងរកឱកាស វិនិយោគ និងបង្កើតអាជីវកម្មថ្មីៗបន្ថែម

តាំងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អតិថិជន ព្រមទាំងកម្មករនិយោជិតគ្រប់លំដាប់ថ្នាក់ ក្រុមប្រឹក្សាភិបាល និងភាគទុនិក ដែលតែងតែជួយគាំទ្រទាំងកម្លាំងកាយ កម្លាំងចិត្ត និងសហការយ៉ាងពេញទំហឹងតាំងពីដើមរៀងមក ធ្វើឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី ទទួលបានជោគជ័យ និងរីកចម្រើនជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនដល់សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា និងកម្មករនិយោជិតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី គ្រប់លំដាប់ថ្នាក់ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# រចនាសម្ព័ន្ធគ្រប់គ្រង



# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឈុន ស្រ៊ា**

*ប្រធានក្រុមប្រឹក្សាភិបាល*

## លោក ឈុន ស្រ៊ា ប្រធានក្រុមប្រឹក្សាភិបាល

សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៥៣ ។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺន ជាច្រើនទាក់ទងនឹងការគ្រប់គ្រង ចាត់ចែងអាជីវកម្ម។ បច្ចុប្បន្នលោកមាននាទីជាអ្នកចាត់ចែងជាន់ខ្ពស់នៅក្នុងក្រុមហ៊ុនប្រេងឥន្ធនៈមួយ។ មុនពេលតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល លោកគឺជាស្ថាបនិកម្នាក់ និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់និរន្តរ ចាប់តាំងពីបង្កើតក្នុងឆ្នាំ២០១៣ មក។

## លោក ឈុន ស៊ីណា អភិបាល

សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៨៣ ។ លោកបានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យបៀលប្រាយ ជំនាញគ្រប់គ្រងទូទៅនៅឆ្នាំ២០១១ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺន ជាច្រើន ទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកគឺជាស្ថាបនិកម្នាក់របស់និរន្តរ ចាប់តាំងពីបង្កើតនៅក្នុងឆ្នាំ២០១៣ មក។ មុនពេលតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ លោកធ្លាប់មានបទពិសោធន៍ ជាមន្ត្រីឥណទាន ជាគណនេយ្យករ នាយនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធាននាយកហិរញ្ញវត្ថុ។




**លោក ឈុន ស៊ីណា**

*អភិបាល*

## លោកស្រី ឈុន វ៉ាន់ណាល់  អភិបាល

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨៦លោកស្រីទទួលបានបរិញ្ញាបត្រជំនាញគណនេយ្យ។ លោកស្រីធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺន ជាច្រើនទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកស្រីត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់និរន្តរ នៅឆ្នាំ២០២០។ មុនពេលតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់និរន្តរ លោកស្រីធ្លាប់មានបទពិសោធន៍៖ ពាណិជ្ជករ (អាជីវកម្មប្រេងឥន្ធនៈ និងមីនីម៉ាត) និងជាភាគទុនិក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្ត។



**លោកស្រី ឈុន វ៉ាន់ណាល់**

*អភិបាល*



**លោក នុត សំអាត**

*អភិបាលឯករាជ្យ*

## លោក នុត សំអាត អភិបាលឯករាជ្យ

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨៣ លោកទទួលបានសញ្ញាបត្រគណនេយ្យករជំនាញនៅឆ្នាំ២០១០។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលឯករាជ្យរបស់និរន្តរនៅឆ្នាំ២០២០។ មុនពេលតែងតាំងជាក្រុមប្រឹក្សាភិបាលឯករាជ្យរបស់និរន្តរ លោកធ្លាប់មានបទពិសោធន៍ធ្វើជា៖ ជំនួយការនាយកប្រតិបត្តិធនាគារអេស៊ីលីដា, ក្រុមប្រឹក្សាភិបាលឯករាជ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទ្រព្យខ្ញុំ និងសហកម្មសិទ្ធករក្រុមហ៊ុនPCG &Partner។

# សមាសភាពគណៈគ្រប់គ្រង



## លោក ឈុន ស៊ីណា ប្រធាននាយកប្រតិបត្តិ

សញ្ញាតិខ្មែរ កើតនៅឆ្នាំ ១៩៨៣ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យបៀលប្រាយ ជំនាញគ្រប់គ្រងទូទៅនៅឆ្នាំ២០១១ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកគឺជាស្ថាបនិកម្នាក់របស់និរន្តរ ចាប់តាំងពីផ្តើតនៅក្នុងឆ្នាំ២០១៣ មក។ មុនពេលតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ លោកធ្លាប់មានបទពិសោធន៍ជាមន្ត្រីឥណទាន ជាគណនេយ្យករ នាយកនាយកដ្ឋានហិរញ្ញវត្ថុ និងប្រធាននាយកហិរញ្ញវត្ថុ ។



## លោក កៀត វីរៈ
## ប្រធានមុខងារប្រតិបត្តិតាម

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨២ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យបៀលប្រាយ ជំនាញគ្រប់គ្រងទូទៅនៅឆ្នាំ២០០៨ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទង នឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោក ត្រូវបានតែងតាំងជាប្រធានមុខងារប្រតិបត្តិតាម។ មុនពេលចូលបម្រើការងារជាមួយ និរន្តរ លោកធ្លាប់មានបទពិសោធន៍ ជាអ្នកធ្វើ និងគ្រប់គ្រងការងាររដ្ឋបាលអស់រយៈពេលជាច្រើនឆ្នាំ នៅធនាគារ អេស៊ីលីដាភីអិស៊ី។



## លោក មាស វ៉ាន់ដេត
## នាយកនាយកដ្ឋានព័ត៌មានវិទ្យា

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៧៤ លោកទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញជំនាញបច្ចេកវិទ្យាព័ត៌មាននៅ ឆ្នាំ២០០៧ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ ក្រៅពីបម្រើការងារជាមួយនិរន្តរ លោកក៏ជា សាស្ត្រាចារ្យផ្នែកព័ត៌មានវិទ្យាមួយរូបនៅសាកលវិទ្យា ល័យភូមិន្ទភ្នំពេញផងដែរ។



## លោក ភា ច័ន្ទពិសិដ្ឋ
## នាយកនាយកដ្ឋានឥណទាន

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨៤ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅឆ្នាំ២០១៣ លោកចូលបម្រើការងារជាមួយនិរន្តរដំបូងក្នុងឆ្នាំ២០១៥ ក្នុងតួនាទីជានាយករងនាយកដ្ឋានឥណទាន និងត្រូវបានតែងតាំងជានាយកនាយកដ្ឋានឥណទានក្នុងឆ្នាំ២០១៧។ មុនចូលបម្រើការងារជាមួយនិរន្តរ លោកធ្លាប់មានបទពិសោធន៍ប្រមាណ ៨ ឆ្នាំ ក្នុងវិស័យឥណទានពីធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។



## លោក ឡេង ល័ក្ខ
## នាយកនាយកដ្ឋានហិរញ្ញវត្ថុ

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨២លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យន័រតុន ជំនាញធនាគារ និងហិរញ្ញវត្ថុនៅឆ្នាំ២០១៥ និងកំពុងបន្តការសិក្សាថ្នាក់ ACCA នៅវិទ្យាស្ថាន CamEd ។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងនឹងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំងជា នាយកនាយកដ្ឋានហិរញ្ញវត្ថុ ។ មុនពេលចូលបម្រើការងារជាមួយនិរន្តរ លោកធ្លាប់មានបទពិសោធន៍ជាអ្នកធ្វើ និងគ្រប់គ្រងការងារសវនកម្មផ្ទៃក្នុងនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជាច្រើនឆ្នាំ។



## លោក ប៊ី វិចិត្រ
## នាយកនាយកដ្ឋានធនធានមនុស្ស

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨៨លោកបានទទួល សញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពី សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ជំនាញជំនាញផ្នែក គ្រប់គ្រងពាណិជ្ជកម្ម, ជំនាញផ្នែកធុរកិច្ច នៅឆ្នាំ២០១២ និងធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺន ជាច្រើនដូចជាភាពជាអ្នកដឹកនាំ, ទីផ្សារ, ធនធានមនុស្ស។លោកត្រូវបានតែងតាំងជានាយកនាយកដ្ឋានធនធានមនុស្សរបស់និរន្តរនៅឆ្នាំ២០១៩។ មុនពេលចូលបម្រើការងារជាមួយ និរន្តរ លោកធ្លាប់មានបទពិសោធន៍ជាអ្នកធ្វើ និងគ្រប់គ្រងការងារធនធានមនុស្សនៅ អិល អ៊ី ឌី អេ ឃែភីថល ភីអិលស៊ី ជាច្រើនឆ្នាំ។



## លោក ឆាន់ ធីរក្ស
## នាយកនាយកដ្ឋានសវនកម្ម

សញ្ញាតិខ្មែរ កើតនៅឆ្នាំ១៩៨៧លោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យន័រតុន ជំនាញគ្រប់គ្រងពាណិជ្ជកម្មនៅឆ្នាំ២០១៣។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើនទាក់ទងនឹងសវនកម្មនិងការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ។ លោកត្រូវបានតែងតាំង ជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់និរន្តរនៅឆ្នាំ២០២០។ មុនពេលតែងតាំងជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់និរន្តរ លោកធ្លាប់មានបទពិសោធន៍ធ្វើជា៖ សវនករផ្ទៃក្នុង, សវនករឯកទេសផ្នែកសវនកម្មប្រតិបត្តិការ, សវនករជាន់ខ្ពស់ផ្នែកសវនកម្មហិរញ្ញវត្ថុ និងប្រធានផ្នែកសវនកម្មហិរញ្ញវត្ថុ ។

# របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

និងរបាយការណ៍របស់សវនករឯករាជ្យ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយ ក្នុងការដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀតដល់អតិថិជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលនៃហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ៣០០,៤២៥ | ១,២២៤,៨៣២ | ១១១,៨៤៣ | ៤៥៣,១៨៧ |
| ពន្ធលើប្រាក់ចំណេញ | (៧៩,៣១៣) | (៣២៣,៣៥៩) | (៤០,៩០៤) | (១៦៥,៧៤៣) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២២១,១១២ | ៩០១,៤៧៣ | ៧០,៩៣៩ | ២៨៧,៤៤៤ |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនោះទេ។

## ដើមទុន

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ មានចំនួន ២,៥៥៧,៧៦៥ ដុល្លារអាមេរិក (២០១៩: ២,៥៥៧,៧៦៥ ដុល្លារអាមេរិក) ដែលក្នុងមួយភាគហ៊ុនមានតម្លៃស្មើនឹង ១ (មួយ) ដុល្លារអាមេរិក។ ភាគហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ទី ១២។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬ អាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្តនិងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាល ក៏មានមតិផងដែរថានៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក ឈុន ស្រ៊ា | ប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២០) |
| លោក ឡាយ គឹមឆេន | ប្រធានក្រុមប្រឹក្សាភិបាល (លាលែងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២០) |
| លោក ឈុន ស៊ីណា | អភិបាល |
| អ្នកស្រី ឈុន វ៉ាន់ណាល់ | អភិបាល (តែងតាំងនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២០) |
| លោក នុត សំអាត | អភិបាលឯករាជ្យ (តែងតាំងនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២០) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ១២ នៃរបាយការហិរញ្ញវត្ថុ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទ ឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (ត)

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់ និងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និងព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាម CIFRS for SMEs ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណឲ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំបាទតំណាងឲ្យអ្នកគ្រប់គ្រងរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី ២៦ ដល់ ៦៤ ថាបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល*

លោក ឈុន ស៊ីណា

*អភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២១

# របាយការណ៍របស់សវនករឯករាជ្យ
# ជូនចំពោះភាគទុនិក
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និវន្តរ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញនៅ ទំព័រទី ២៦ ដល់ ៦៤។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំគឺឯករាជ្យពីក្រុមហ៊ុន តាមតម្រូវការនៃក្រមសីលធម៌ដែលពាក់ព័ន្ធនឹង ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាមតម្រូវការទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ការទាញចំណាប់អារម្មណ៍លើបញ្ហា - ព័ត៌មានប្រៀបធៀប

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ ២២ នៃរបាយកាណ៍ហិរញ្ញវត្ថុដែលបង្ហាញថា ព័ត៌មានប្រៀបធៀបដែលបានបង្ហាញនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ និងសម្រាប់ការិយបរិច្ឆេទដែលបញ្ចប់ត្រូវបានកំណត់ឡើងវិញ។ មតិសវនកម្មរបស់យើងខ្ញុំ មិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ត្រូវបានធ្វើសវនកម្មដោយសវនករដ៏ទៃទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០២០ ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ ១៧ ដល់ទី ២១ ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឲ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានផ្តល់នូវអំណះអំណាងណាមួយលើព័ត៌មានផ្សេងៗទាំងនេះឡើយ។ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះអាចឲ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យលើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង របស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)

យើងខ្ញុំ បានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវ លើអភិបាលកិច្ច ចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមាន ជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុក សម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្ត រួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **អេហ្វអាយអាយ & អឺសូស៊ីអេត**

**ហេង សិតា**

*នាយកគ្រប់គ្រង*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សម្គាល់២.៤) | ២០១៩ (កំណត់ឡើងវិញ) ដុល្លារអាមេរិក | ២០១៩ (កំណត់ឡើងវិញ) ពាន់រៀល (កំណត់សម្គាល់២.៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ៤៨,០៥៩ | ១៩៤,៣៩៩ | ៦០,០៣៣ | ២៤៤,៦៣៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៥ | ១៣៨,១៩៤ | ៥៥៨,៩៩៥ | ១៣៧,៤២៩ | ៥៦០,០២៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ៦ | ២,៤០៤,៨៥៣ | ៩,៧២៧,៦៣០ | ២,០១៥,៣៥៤ | ៨,២១២,៥៦៨ |
| ឥណទានផ្ដល់ដល់អតិថិជន | ៧ | ១,៣៧៤,១៧៤ | ៥,៥៥៨,៥៣៤ | ១,៦០៧,៧៥៩ | ៦,៥៥១,៦១៨ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ១៦០,២១៨ | ៦៤៨,០៨២ | ២៤៣,៧៩៦ | ៩៩៣,៤៦៩ |
| ទ្រព្យ និងបរិក្ខារ | ៩ | ៧៧,៩៨៤ | ៣១៥,៤៤៥ | ៧៧,៧៤៩ | ៣១៦,៨២៧ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១១.១ | ៦,៣៧៩ | ២៥,៨០៣ | ១១,៥៩៣ | ៤៧,២៤២ |
| **ទ្រព្យសកម្មសរុប** | | ៤,២០៩,៨៦១ | ១៧,០២៨,៨៨៨ | ៤,១៥៣,៧១៣ | ១៦,៩២៦,៣៨១ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១០ | ១៣០,៩៩៩ | ៥២៩,៨៩១ | ៣៣៦,២៨៤ | ១,៣៧០,៣៥៨ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១១.២ | ៨៨,៥៣៥ | ៣៥៨,១២៤ | ៤៨,២១៤ | ១៩៦,៤៧២ |
| **បំណុលសរុប** | | ២១៩,៥៣៤ | ៨៨៨,០១៥ | ៣៨៤,៤៩៨ | ១,៥៦៦,៨៣០ |
| **មូលធន** | | | | | |
| ដើមទុន | ១២ | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៣ | - | - | ២០,៦៨៨ | ៨៤,៣០៤ |
| ប្រាក់ចំណេញរក្សាទុក | | ១,៤៣២,៥៦២ | ៥,៨០២,៨០០ | ១,១៩០,៧៦២ | ៤,៨១៦,៩៨២ |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | | - | ១០៧,០១៣ | - | ២២៧,២០៥ |
| **មូលធនសរុប** | | ៣,៩៩០,៣២៧ | ១៦,១៤០,៨៧៣ | ៣,៧៦៩,២១៥ | ១៥,៣៥៩,៥៥១ |
| **បំណុល និងមូលធនសរុប** | | ៤,២០៩,៨៦១ | ១៧,០២៨,៨៨៨ | ៤,១៥៣,៧១៣ | ១៦,៩២៦,៣៨១ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លទ្ធផលលម្អិត
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់ | | | ២០១៩ | |
|---|---|---|---|---|---|
| | | ២០២០ | | (កំណត់ឡើងវិញ) | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ចំណូលពីការប្រាក់ | ១៤ | ២៦៨,០៥៤ | ១,០៩២,៨៥៦ | ៣០៦,៩៦២ | ១,២៤៣,៨១០ |
| ចំណូលកម្រៃ និងជើងសារ | | ១,៤៣៨,៦៧៦ | ៥,៨៦៥,៤៨២ | ១,៦៣៤,៥៤៦ | ៦,៦២៣,១៨០ |
| ចំណូលផ្សេងៗ | | ៤៨,៩០២ | ១៩៩,៣៧៣ | ៨៩,២៧៧ | ៣៦១,៧៥០ |
| **ចំណូលប្រតិបត្តិការសរុប** | | ១,៧៥៥,៦៣២ | ៧,១៥៧,៧១១ | ២,០៣០,៧៨៥ | ៨,២២៨,៧៤០ |
| រំលស់ | | (១៨,១៦២) | (៧៤,០៤៦) | (២៨,០៥៩) | (១១៣,៦៩៥) |
| ចំណាយទូទៅ និងរដ្ឋបាល | ១៥ | (១,២៤៥,៧៧៣) | (៥,០៧៩,០១៧) | (១,៨៦៨,៩០១) | (៧,៥៧២,៧៨៧) |
| ការខាតបង់លើឱនភាពនៃទ្រព្យសកម្ម ហិរញ្ញវត្ថុ | ៧ | (១៩១,២៧២) | (៧៧៩,៨១៦) | (២១,៩៨២) | (៨៩,០៧១) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៣០០,៤២៥ | ១,២២៤,៨៣២ | ១១១,៨៤៣ | ៤៥៣,១៨៧ |
| ពន្ធលើប្រាក់ចំណេញ | ១១.៣ | (៧៩,៣១៣) | (៣២៣,៣៥៩) | (៤០,៩០៤) | (១៦៥,៧៤៣) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | ២២១,១១២ | ៩០១,៤៧៣ | ៧០,៩៣៩ | ២៨៧,៤៤៤ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១២០,១៩២) | - | ១៦៦,៩៥៨ |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | ២២១,១១២ | ៧៨១,២៨១ | ៧០,៩៣៩ | ៤៥៤,៤០២ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក (កំណត់ឡើងវិញ) | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ៥,០៥៧,៧៦៥ | ២០,២៣១,០៦០ | - | - | ១,១៤០,៥១១ | ៤,៦១៣,៣៦៦ | - | ៦០,២៤៧ | ៦,១៩៨,២៧៦ | ២៤,៩០៤,៦៧៣ |
| **ប្រតិបត្តិការជាមួយភាគទុនិកទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន** | | | | | | | | | | |
| ការបន្ថយដើមទុន | (២,៥០០,០០០) | (១០,០០០,០០០) | - | - | - | - | - | - | (២,៥០០,០០០) | (១០,០០០,០០០) |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ (កំណត់ឡើងវិញ) | - | - | - | - | ៧០,៩៣៩ | ២៨៧,៤៤៤ | - | - | ៧០,៩៣៩ | ២៨៧,៤៤៤ |
| ផ្ទេរ | - | - | ២០,៦៨៨ | ៨៣,៨២៨ | (២០,៦៨៨) | (៨៣,៨២៨) | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | |
| *លម្អៀងពីការប្តូររូបិយប័ណ្ណ* | - | - | - | ៤៧៦ | - | - | - | ១៦៦,៩៥៨ | - | ១៦៧,៤៣៤ |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | ២០,៦៨៨ | ៨៤,៣០៤ | ៥០,២៥១ | ២០៣,៦១៦ | - | ១៦៦,៩៥៨ | ៧០,៩៣៩ | ៤៥៤,៨៧៨ |
| **នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩** | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ | ២០,៦៨៨ | ៨៤,៣០៤ | ១,១៩០,៧៦២ | ៤,៨១៦,៩៨២ | - | ២២៧,២០៥ | ៣,៧៦៩,២១៥ | ១៥,៣៥៩,៥៥១ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ | ២០,៦៨៨ | ៨៤,៣០៤ | ១,១៩០,៧៦២ | ៤,៨១៦,៩៨២ | - | ២២៧,២០៥ | ៣,៧៦៩,២១៥ | ១៥,៣៥៩,៥៥១ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២២១,១១២ | ៩០១,៤៧៣ | - | - | ២២១,១១២ | ៩០១,៤៧៣ |
| ផ្ទេរ | - | - | (២០,៦៨៨) | (៨៤,៣៤៥) | ២០,៦៨៨ | ៨៤,៣៤៥ | | | - | - |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៤១ | - | - | - | (១២០,១៩២) | - | (១២០,១៥១) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | (២០,៦៨៨) | (៨៤,៣០៤) | ២៤១,៨០០ | ៩៨៥,៨១៨ | - | (១២០,១៩២) | ២២១,១១២ | ៧៨១,៣២២ |
| **នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០** | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ | - | - | ១,៤៣២,៥៦២ | ៥,៨០២,៨០០ | - | ១០៧,០១៣ | ៣,៩៩០,៣២៧ | ១៦,១៤០,៨៧៣ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២២១,១១២ | ៩០១,៤៧៣ | ៧០,៩៣៩ | ២៨៧,៤៤៤ |
| និយ័តភាពលើ៖ | | | | |
| ពន្ធលើប្រាក់ចំណេញ | ៧៩,៣១៣ | ៣២៣,៣៥៩ | ៤០,៩០៤ | ១៦៥,៧៤៣ |
| ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | ១៩១,២៧២ | ៧៧៩,៨១៦ | ២១,៩៨២ | ៨៩,០៧១ |
| រំលស់ | ១៨,១៦២ | ៧៤,០៤៦ | ២៨,០៥៩ | ១១៣,៦៩៥ |
| ទ្រព្យ និងបរិក្ខារដែលបានលុបចោល | ១៧២ | ៧០១ | ២,៥៥០ | ១០,៣៣៣ |
| ឥណទានដែលបានលុបចោល | - | - | (៦៤,២៧៤) | (២៦០,៤៣៨) |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | (៥,៧៤៧) | (២៣,៤៣១) | (១៣,៦៦៤) | (៥៥,៣៦៧) |
| | ៥០៤,២៨៤ | ២,០៥៥,៩៦៤ | ៨៦,៤៩៦ | ៣៥០,៤៨១ |
| **បម្រែបម្រួលនៃ៖** | | | | |
| ឥណទានផ្តល់ដល់អតិថិជន | ៤២,៣១៣ | ១៧២,៥១០ | ២៩,៧៧៥ | ១២០,៦៤៨ |
| ទ្រព្យសកម្មផ្សេងៗ | ៨៣,៥៧៨ | ៣៤០,៧៤៨ | ៧,៦៨៣ | ៣១,១៣២ |
| បំណុលផ្សេងៗ | (២០៥,២៨៥) | (៨៣៦,៩៤៧) | ៧១,១៥១ | ២៨៨,៣០៤ |
| | ៤២៤,៨៩០ | ១,៧៣២,២៧៥ | ១៩៥,១០៥ | ៧៩០,៥៦៥ |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (៣៣,៧៧៨) | (១៣៧,៧១៣) | (២០,៧៤៦) | (៨៤,០៦៣) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | ៣៩១,១១២ | ១,៥៩៤,៥៦២ | ១៧៤,៣៥៩ | ៧០៦,៥០២ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (១៨,៥៦៩) | (៧៥,៧០៦) | (២,៦៩៨) | (១០,៩៣២) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | ៥,៧៤៧ | ២៣,៤៣១ | ១៣,៧១១ | ៥៥,៥៥៧ |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពវិនិយោគ** | (១២,៨២២) | (៥២,២៧៥) | ១១,០១៣ | ៤៤,៦២៥ |

# របាយការណ៍លំហូរសាច់ប្រាក់ (ត)
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ការបន្ថយដើមទុន | - | - | (២,៥០០,០០០) | (១០,០០០,០០០) |
| ការដកប្រាក់តម្កល់ពីធនាគាជាតិនៃកម្ពុជា | - | - | ១២៥,០០០ | ៥០៦,៥០០ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពហិរញ្ញប្បទាន** | - | - | (២,៣៧៥,០០០) | (៩,៤៩៣,៥០០) |
| **ការកើនឡើង/(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | ៣៧៨,២៩០ | ១,៥៤២,២៨៧ | (២,១៨៩,៦២៨) | (៨,៧៤២,៣៧៣) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី ១ ខែ មករា | ២,០៨៤,៩២៨ | ៨,៤៩៦,០៨១ | ៤,២៧៤,៥៥៦ | ១៧,១៧៥,១៦៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៧៤,៦៥១) | - | ៦៣,២៨៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី ៣១ ខែ ធ្នូ (កំណត់សម្គាល់ ១៦)** | ២,៤៦៣,២១៨ | ៩,៩៦៣,៧១៧ | ២,០៨៤,៩២៨ | ៨,៤៩៦,០៨១ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

## ១. ព័ត៌មានអំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និរន្តរ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវបានបង្កើតឡើង និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១៣ ក្រោមបញ្ជីពាណិជ្ជកម្មលេខ ០០០០៧៤៦៩ ចេញដោយក្រសួងពាណិជ្ជកម្ម។

នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណអចិន្ត្រៃយ៍ដល់ក្រុមហ៊ុនដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀតដល់អតិថិជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នក្រុមហ៊ុនធ្វើប្រតិបត្តិការតាមរយៈ ស្នាក់ការកណ្តាលនៅក្រុងភ្នំពេញ និងដប់សាខាផ្សេងទៀតដែលមានទីតាំងនៅបណ្តាខេត្តផ្សេងៗទៀត។

ក្រុមហ៊ុនមានការិយាល័យកណ្តាលនៅផ្ទះលេខ ២១-២៣-២៥ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ក្រុមហ៊ុនមានបុគ្គលិកសរុបចំនួន ២០០ នាក់ (ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ មានចំនួន ២០២ នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ

### ២.១ របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

ព័ត៌មានលម្អិតស្តីអំពីគោលនយោបាយគណនេយ្យសំខាន់ៗរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញនៅក្នុង កំណត់សម្គាល់ ២១។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តសម្រេចដោយក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២១។

### ២.២ ការិយបរិច្ឆេទសារពើពន្ធ និងការិយបរិច្ឆេទរាយការណ៍

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ។

### ២.៣ មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម។

## ២.៤ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺប្រាក់រៀល ។ ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានរូបិយប័ណ្ណពីរប្រភេទ ជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញព្រោះវាបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។ តួលេខទាំងអស់ត្រូវបានបង្គត់ឡើងចុះទៅនឹងតួលេខដែលនៅជិតបំផុតលើកលែងតែមានការបញ្ជាក់ផ្សេងទៀត។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមតម្រូវការនៃការបង្ហាញ ស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយគណនីដើមទុនត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់ប្រវត្តិសាស្ត្រ។ ដោយឡែករបាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់ គឺត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ។ លម្អៀងលើអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរត្រូវបានកត់ត្រាជាផ្នែកមួយនៅក្នុងមូលធន។ គ្រប់តួលេខជាប្រាក់រៀល ត្រូវបានបង្គត់ជាខ្ទង់ពាន់ឡើងចុះទៅនឹងតួលេខដែលនៅជិតបំផុតហៅកាត់ថា ("ពាន់រៀល") លើកលែងតែមានការបញ្ជាក់ផ្សេង។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| **សម្រាប់ការិយបរិច្ឆេទបញ្ចប់** | **អត្រាចុងគ្រា** | **អត្រាមធ្យម** |
|---|---|---|
| ថ្ងៃទី ៣១ ខែ ធ្នូ ២០២០ | ១ ដុល្លារ = ៤,០៤៥ រៀល | ១ ដុល្លារ = ៤,០៧៧ រៀល |
| ថ្ងៃទី ៣១ ខែ ធ្នូ ២០១៩ | ១ ដុល្លារ = ៤,០៧៥ រៀល | ១ ដុល្លារ = ៤,០៥២ រៀល |

តួលេខជាប្រាក់រៀលនេះ មិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## ២.៥ ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែនិងការិយបរិច្ឆេទអនាគតដែលមានផលប៉ះពាល់ដោយការកែប្រែនោះ។

## ២.៥ ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

ព័ត៌មាននៃការសន្មត និងការប៉ាន់ប្រមាណដែលមានភាពមិនច្បាស់លាស់ ដែលមានផលប៉ះពាល់ខ្លាំងលើការធ្វើនិយ័តកម្ម ក្នុងការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៣ - ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ។

# ៣. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាប្រចាំ ហើយផ្អែកលើបទពិសោធន៍ធ្លាប់មាន និងកត្តាដទៃទៀតរួមទាំងការរំពឹងទុកនៃហេតុការណ៍ដែលធ្លាប់បរាជ័យ ត្រូវបានគេជឿជាក់ថាសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យខ្ពស់ដែលតម្រូវឲ្យធ្វើនិយ័តកម្មលើតម្លៃយោងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទបន្ទាប់ មានដូចខាងក្រោមៈ

## ៣.១ ពន្ធលើប្រាក់ចំណេញ និងពន្ធផ្សេងទៀត

ចំណាយពន្ធត្រូវបានគណនាផ្អែកលើការបកស្រាយចំពោះការអនុវត្តច្បាប់ពន្ធបច្ចុប្បន្ន។ ទោះយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះអាចមានការប្រែប្រួលជារឿយៗ និងមានការបកស្រាយផ្សេងៗគ្នាបន្ទាប់ពីមានការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។ ទាំងនេះអាចបណ្តាលឱ្យមានការកើនឡើងចំណាយពន្ធ និងការទាមទារការទូទាត់ប្រតិសកម្មនៃព្រឹត្តិការណ៍ទាំងនេះ។ វាមានការពិបាកក្នុងការកំណត់ពេលវេលាជាក់លាក់ណាមួយ និងភាពធ្ងន់ធ្ងរនៃការកើតឡើងទាំងនេះ ឬផលប៉ះពាល់របស់វា។

## ៣.២ ទ្រព្យ និងបរិក្ខារ

គណនេយ្យសម្រាប់ទ្រព្យ និងបរិក្ខាររួមបញ្ចូលទាំងការប៉ាន់ស្មាន សម្រាប់កំណត់អាយុកាលនៃការប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ។ ការកំណត់អាយុកាលនៃការប្រើប្រាស់នៃទ្រព្យ និងបរិក្ខារ គឺផ្អែកលើការវិនិច្ឆ័យរបស់អ្នកគ្រប់គ្រង។

## ៣.៣ សំវិធានធនលើបំណុលដែលជាប់សង្ស័យ

អ្នកគ្រប់គ្រងកំណត់សំវិធានធន លើឥណទានដែលជាប់សង្ស័យតាមករណីផ្សេងៗពីគ្នា នៅពេលដែលជឿជាក់ថាការប្រមូលចំនួនទឹកប្រាក់ដែលជំពាក់ទំនងជាមិនអាចកើតឡើង។ ក្នុងការកំណត់ចំនួនសំវិធានធនទាំងនេះ អ្នកគ្រប់គ្រងធ្វើការពិចារណាតាមបទពិសោធន៍ដែលធ្លាប់មាន និងការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន។ ប្រសិនបើស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជនកាន់តែយ៉ាប់យ៉ឺនដែលបណ្តាលឱ្យមានភាពអសមត្ថភាពក្នុងការទូទាត់សង សំវិធានធនតម្រូវឲ្យទទួលស្គាល់តាមអ្វីដែលទទួលបាន។

## ៤. សាច់ប្រាក់ក្នុងដៃ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ប្រាក់រៀល | ៣៦,៥៧៣ | ១៤៧,៩៣៨ | ៥០,៤២៦ | ២០៥,៤៨៥ |
| ដុល្លារអាមេរិក | ១១,៤៨៦ | ៤៦,៤៦១ | ៩,៦០៧ | ៣៩,១៤៩ |
| | ៤៨,០៥៩ | ១៩៤,៣៩៩ | ៦០,០៣៣ | ២៤៤,៦៣៤ |

## ៥. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ប្រាក់តម្កល់ធានាលើដើមទុន(*) | ១២៧,៨៨៨ | ៥១៧,៣០៧ | ១២៧,៨៨៨ | ៥២១,១៤៤ |
| គណនីចរន្ត | ១០,៣០៦ | ៤១,៦៨៨ | ៩,៥៤១ | ៣៨,៨៧៩ |
| | ១៣៨,១៩៤ | ៥៥៨,៩៩៥ | ១៣៧,៤២៩ | ៥៦០,០២៣ |

(*) ប្រាក់តម្កល់ធានាលើដើមទុន ត្រូវបានរក្សាទុកជាមួយធនាគារជាតិនៃកម្ពុជា ស្របតាមប្រកាសលេខ ធ៧-០០-០០៦ ស្តីពីការផ្តល់អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលចំនួនទឹកប្រាក់ត្រូវបានកំណត់ត្រឹម ៥% នៃដើមទុនដែលបានចុះបញ្ជីបស់ក្រុមហ៊ុន។ ប្រាក់តម្កល់នេះ ត្រូវបង្វិលសងវិញនៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន និងមិនមានសល់បំណុលអតិថិជន។

ប្រាក់តម្កល់ ទទួលបានការប្រាក់ក្នុងអត្រា ០.៣៦% ក្នុងមួយឆ្នាំ។

## ៦. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| គណនីចរន្ត | ១,២៨១ | ៥,១៨២ | ១,១០៩ | ៤,៥១៩ |
| គណនីសន្សំ | ២,៤០៣,៥៧២ | ៩,៧២២,៤៤៨ | ២,០១៤,២៤៥ | ៨,២០៨,០៤៩ |
| | ២,៤០៤,៨៥៣ | ៩,៧២៧,៦៣០ | ២,០១៥,៣៥៤ | ៨,២១២,៥៦៨ |

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ ត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

### (ក) តាមកាលកំណត់៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| រយៈពេល ១ ខែ | ២,៤០៤,៨៥៣ | ៩,៧២៧,៦៣០ | ២,០១៥,៣៥៤ | ៨,២១២,៥៦៨ |

### (ខ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)៖

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីចរន្ត | 0.00% | 0.00% |
| គណនីសន្សំ | 0.00% | 0.00% |

## ៧. ឥណទានផ្តល់ដល់អតិថិជន

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ឥណទានផ្តល់ដល់អតិថិជនតាមរំលស់ថ្លៃដើម | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |
| ដកៈ សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ | (១១៩,០៩១) | (៤៨១,៧២៣) | (២១,៩៨២) | (៨៩,៥៧៧) |
| | ១,៣៧៤,១៧៤ | ៥,៥៥៨,៥៣៤ | ១,៦០៧,៧៥៩ | ៦,៥៥១,៦១៨ |

ការប្រែប្រួលនៃសំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោមៈ

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | ២១,៩៨២ | ៨៩,៥៧៧ | ៦៤,២៧៤ | ២៥៨,២៥៣ |
| សំវិធានធនក្នុងការិយបរិច្ឆេទ | ១៩១,២៧២ | ៧៧៩,៨១៦ | ២១,៩៨២ | ៨៩,០៧១ |
| ការលុបចោលឥណទានក្នុងការិយបរិច្ឆេទ | (៩៤,១៦៣) | (៣៨៣,៩០៣) | (៦៤,២៧៤) | (២៦០,៤៣៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣,៧៦៧) | - | ២,៦៩១ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ១១៩,០៩១ | ៤៨១,៧២៣ | ២១,៩៨២ | ៨៩,៥៧៧ |

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖

### (ក) តាមកាលកំណត់៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| តិចជាង ១ ខែ | ១៦៧ | ៦៧៦ | ១១,៩១៥ | ៤៨,៥៥៤ |
| ពី ១ ខែ ទៅ ៣ ខែ | ១,៩៦៤ | ៧,៩៤៤ | ៨៣,៦១០ | ៣៤០,៧១១ |
| ពី ៣ ខែ ទៅ ១២ ខែ | ២២,៩៤៤ | ៩២,៨០៨ | ១,៥៣៣,៨៥២ | ៦,២៥០,៤៤៧ |
| ច្រើនជាង១២ ខែ | ១,៤៦៨,១៩០ | ៥,៩៣៨,៨២៩ | ៣៦៤ | ១,៤៨៣ |
| | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |

### (ខ) តាមប្រភេទរូបិយប័ណ្ណ៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ដុល្លារអាមេរិក | ៥០,៩៧៣ | ២០៦,១៨៦ | ២៣៨,៩៦៨ | ៩៧៣,៧៩៥ |
| ប្រាក់រៀល | ១,៤៤២,២៩២ | ៥,៨៣៤,០៧១ | ១,៣៩០,៧៧៣ | ៥,៦៦៧,៤០០ |
| | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម (ត)៖

### (គ) តាមនិវាសនដ្ឋាន៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| និវាសនជន | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |

### (ឃ) តាមទំនាក់ទំនងសម្ព័ន្ធញាតិ៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| អតិថិជនខាងក្រៅ | ១,៤៦៩,៥៣៤ | ៥,៩៤៤,២៦៥ | ១,៦១៥,៤៨៧ | ៦,៥៨៣,១១០ |
| បុគ្គលិក | ២៣,៧៣១ | ៩៥,៩៩២ | ១៤,២៥៤ | ៥៨,០៨៥ |
| | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម (ត)៖

### (ង) តាមកត្តាសេដ្ឋកិច្ច៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| គ្រួសារ | ៧១៨,៤០៦ | ២,៩០៥,៩៥៣ | ៧៥២,៩៩២ | ៣,០៦៨,៤៤២ |
| កសិកម្ម | ៣១១,៩៨៧ | ១,២៦១,៩៨៧ | ៣៩១,៣៨២ | ១,៥៩៤,៨៨២ |
| ជំនួញ និងពាណិជ្ជកម្ម | ២៧១,២០៦ | ១,០៩៧,០២៨ | ២៥៣,៧១២ | ១,០៣៣,៨៧៦ |
| សេវាកម្ម | ១៣១,០១១ | ៥២៩,៩៣៩ | ១៨៦,៨៣៤ | ៧៦១,៣៤៩ |
| សំណង់ | ១២,៣៧៤ | ៥០,០៥៣ | ១៣,៩៦៩ | ៥៦,៩២៤ |
| មធ្យោបាយដឹកជញ្ជូន | ១,១៤៩ | ៤,៦៤៨ | ៤,១៧៩ | ១៧,០២៩ |
| ផ្សេងៗ | ៤៧,១៣២ | ១៩០,៦៤៩ | ២៦,៦៧៣ | ១០៨,៦៩៣ |
| | ១,៤៩៣,២៦៥ | ៦,០៤០,២៥៧ | ១,៦២៩,៧៤១ | ៦,៦៤១,១៩៥ |

### (ច) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

| | ២០២០ | ២០១៩ |
|---|---|---|
| ឥណទានឯកត្តជន | ១៨% | ១៨% |
| ឥណទាននីតិជន | ១៨% | ១៨% |

## ៨. ទ្រព្យសកម្មផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ការទូទាត់មុន | ១១៦,៨០៨ | ៤៧២,៤៨៨ | ២០០,៣៤៤ | ៨១៦,៤០២ |
| ប្រាក់កក់ | ៤៣,៤១០ | ១៧៥,៥៩៤ | ៤៣,៤៥២ | ១៧៧,០៦៧ |
| | ១៦០,២១៨ | ៦៤៨,០៨២ | ២៤៣,៧៩៦ | ៩៩៣,៤៦៩ |

## ៩. ទ្រព្យ និងបរិក្ខារ

| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ការកែលំអ អាគារជួល ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | បរិក្ខារការិយាល័យ និងបរិក្ខារផ្សេងៗ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ១២១,៨០៦ | ៣២,១១៩ | ៩៩,៦៦៨ | ៧១,១៣០ | ៦៥,៦៦២ | ៣៩០,៣៨៥ | ១,៥៩០,៨១៩ |
| ការទិញបន្ថែម | ១៤,១៧៨ | ៣៨៦ | ២,៣៥៥ | ១,៦៥០ | - | ១៨,៥៦៩ | ៧៥,៧០៦ |
| ការលក់ | - | - | - | (៤,១៦០) | (១៧,៦៩៧) | (២១,៨៥៧) | (៨៩,១១១) |
| ការលុបចោល | - | - | (១០,១១២) | (១,៣៦៥) | (១,៣៧០) | (១២,៨៤៧) | (៥២,៣៧៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (១១,១៩៦) |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ១៣៥,៩៨៤ | ៣២,៥០៥ | ៩១,៩១១ | ៦៧,២៥៥ | ៤៦,៥៩៥ | ៣៧៤,២៥០ | ១,៥១៣,៨៤១ |
| ដក៖ **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ៥៣,៣៤០ | ៣១,៣៣៦ | ៩៥,៤១០ | ៦៧,៧៦១ | ៦៤,៧៨៩ | ៣១២,៦៣៦ | ១,២៧៣,៩៩២ |
| រំលស់ក្នុងការិយបរិច្ឆេទ | ២០,៧១៩ | ៧៤០ | ២០ | ៤,៧៤៦ | ២៤០ | ២៦,៤៦៥ | ១០៧,៨៩៨ |
| ការលក់ | - | - | - | (៤,១៦០) | (១៧,៦៩៧) | (២១,៨៥៧) | (៨៩,១១១) |
| ការលុបចោល | - | - | (១០,១១១) | (១,១៩៣) | (១,៣៧១) | (១២,៦៧៥) | (៥១,៦៧៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (៩,១២២) |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ៧៤,០៥៩ | ៣២,០៧៦ | ៨៥,៣១៩ | ៦៧,១៥៤ | ៤៥,៩៦១ | ៣០៤,៥៦៩ | ១,២៣១,៩៨១ |
| **តម្លៃយោង** | | | | | | | |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ៦១,៩២៥ | ៤២៩ | ៦,៥៩២ | ១០១ | ៦៣៤ | ៦៩,៦៨១ | ២៨១,៨៦០ |

## ៩. ទ្រព្យ និងបរិក្ខារ (ត)

| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ការកែលំអ អាគារជួល ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | បរិក្ខារការិយាល័យ និងបរិក្ខារផ្សេងៗ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់ ២.៤) |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ១២១,៨០៦ | ៣៤,៤០៩ | ១១៩,៥៩២ | ៧៧,៦៥៩ | ៩៨,៤៥៧ | ៤៥១,៩២៣ | ១,៨១៥,៨២៧ |
| ការទិញបន្ថែម | - | - | ១,១៦០ | ៥៣៨ | ១,០០០ | ២,៦៩៨ | ១០,៩៣២ |
| ការលក់ | - | (៣៣) | (១០,៥២៦) | (៨៦៨) | (៣១,១១៨) | (៤២,៥៤៥) | (១៧២,៣៩២) |
| ការលុបចោល | - | (២,២៥៧) | (១០,៥៥៨) | (៦,១៩៩) | (២,៦៧៧) | (២១,៦៩១) | (៨៧,៨៩២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ២៤,៣៤៤ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ១២១,៨០៦ | ៣២,១១៩ | ៩៩,៦៦៨ | ៧១,១៣០ | ៦៥,៦៦២ | ៣៩០,៣៨៥ | ១,៥៩០,៨១៩ |
| ដក៖ **រំលស់បង្គរ** | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ៤៣,៨២០ | ៣២,០៥០ | ១០៦,៦៣៤ | ៧២,០៨០ | ៩៤,៤៣២ | ៣៤៩,០១៦ | ១,៤០២,៣៤៧ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៩,៥២០ | ១,៥៧៦ | ៩,៨១៣ | ២,៧៤៨ | ៤,១៥២ | ២៧,៨០៩ | ១១២,៦៨២ |
| ការលក់ | - | (៣៣) | (១០,៤៧៩) | (៨៦៧) | (៣១,១១៨) | (៤២,៤៩៧) | (១៧២,១៩៨) |
| ការលុបចោល | - | (២,២៥៧) | (១០,៥៥៨) | (៦,១៩៩) | (២,៦៧៨) | (២១,៦៩២) | (៨៧,៨៩៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ១៩,០៥៧ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៥៣,៣៤០ | ៣១,៣៣៦ | ៩៥,៤១០ | ៦៧,៧៦២ | ៦៤,៧៨៨ | ៣១២,៦៣៦ | ១,២៧៣,៩៩២ |
| **តម្លៃយោង** | | | | | | | |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៦៨,៤៦៦ | ៧៨៣ | ៤,២៥៨ | ៣,៣៦៨ | ៨៧៤ | ៧៧,៧៤៩ | ៣១៦,៨២៧ |

## ១០. បំណុលផ្សេងៗ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| សំវិធានធនលើប្រាក់អតីតភាពការងារ (*) | ៥៦,១៩១ | ២២៧,២៩៣ | ៦៧,៣៣៥ | ២៧៤,៣៩០ |
| ប្រាក់លើកទឹកចិត្ត និងចំណាយ | ៥២,៩៧៤ | ២១៤,២៨០ | ២៣៣,៨៤២ | ៩៥២,៩០៦ |
| ចំណាយបង្គរ | ៥,២២៨ | ២១,១៤៧ | ១៧,៧០០ | ៧២,១២៨ |
| បំណុលពន្ធកាត់ទុក | ៣,៤៥១ | ១៣,៩៥៩ | ៤,១៥៣ | ១៦,៩២៣ |
| ផ្សេងៗ | ១៣,១៥៥ | ៥៣,២១២ | ១៣,២៥៤ | ៥៤,០១១ |
| | ១៣០,៩៩៩ | ៥២៩,៨៩១ | ៣៣៦,២៨៤ | ១,៣៧០,៣៥៨ |

(*) សំវិធានធននេះតំណាងឱ្យការផ្តល់ប្រាក់សំណងអតីតភាពការងារដែលតម្រូវដោយប្រកាសលេខ ៤៤៣ ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨ និងត្រូវបានធ្វើវិសោធនកម្មបន្ទាប់ដោយសេចក្តីណែនាំលេខ ០៤២/១៩ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៩។ ប្រកាសនេះតម្រូវឱ្យនិយោជកទាំងអស់ ទូទាត់សំណងអតីតភាពដល់និយោជិតរបស់ពួកគេដូចខាងក្រោម៖

(ក) ប្រាក់អតីតភាពការងារបច្ចុប្បន្ន ចាប់ផ្តើមពីឆ្នាំ ២០១៩ តទៅក្នុងចំនួនទឹកប្រាក់ស្មើនឹង ១៥ ថ្ងៃនៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងមួយឆ្នាំ។

(ខ) ប្រាក់រំលឹកអតីតភាពការងារ៖ ចាប់ផ្តើមពីឆ្នាំ ២០២១ តទៅក្នុងបរិមាណស្មើនឹងប្រាក់ឈ្នួលសុទ្ធ ៦ ថ្ងៃក្នុងមួយឆ្នាំ។ ការផ្តល់ប្រាក់បំណាច់អតីតភាពការងារត្រូវបានគណនានៅប្រាក់ឈ្នួល ៦ ថ្ងៃ និងអត្ថប្រយោជន៍ផ្សេងៗទៀតក្នុងមួយឆ្នាំនៃប្រាក់ឈ្នួលសុទ្ធ និងមិនលើសពី ៦ ខែ (អាស្រ័យលើរយៈពេលនៃសេវាកម្មដែលបានបម្រើ) ដល់និយោជិតដែលមានអតីតភាពការងារមុនឆ្នាំ ២០១៩។

ការទូទាត់នឹងត្រូវធ្វើឡើងពីរដងក្នុងមួយឆ្នាំ គឺនៅខែមិថុនា និងខែធ្នូ។ និយោជិតមិនមានសិទ្ធិទទួលបានប្រាក់សំណងអតីតភាពដែលនៅសល់មិនទាន់ដល់ពេលកំណត់ ប្រសិនបើគាត់លាឈប់ពីក្រុមហ៊ុន។

## ១០. ចំណូលផ្សេងៗ (ត)

បម្រែបម្រួលសំវិធានធនសម្រាប់អត្ថប្រយោជន៍និយោជិកក្នុងឆ្នាំ មានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | ៦៧,៣៣៥ | ២៧៤,៣៩០ | ៦៧,៣៣៥ | ២៧០,៥៥២ |
| សំវិធានធនក្នុងឆ្នាំ | ៣២,៩៦៥ | ១៣៤,៣៩៨ | - | - |
| ដកចេញ | (៤៤,១០៩) | (១៧៩,៨៣២) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១,៦៦៣) | - | ៣,៨៣៨ |
| នាថ្ងៃទី ១ ខែ ធ្នូ | ៥៦,១៩១ | ២២៧,២៩៣ | ៦៧,៣៣៥ | ២៧៤,៣៩០ |

## ១១. ពន្ធលើប្រាក់ចំណេញ

### ១១.១ ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ

ពន្ធពន្យារជាទ្រព្យសកម្ម និងជាបំណុល គឺត្រូវបានកាត់កងទៅនៅពេលដែលមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងពន្ធជាទ្រព្យសកម្ម ជាមួយនឹងបំណុលពន្ធ ហើយនិងនៅពេលដែលពន្ធពន្យារទាក់ទងទៅនឹងអាជ្ញាធរពន្ធដារដូចគ្នា។

ចំនួនទឹកប្រាក់ខាងក្រោមដែលត្រូវបានកំណត់បន្ទាប់ពីកាត់កងសមស្រប ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១១,០៣២ | ៤៤,៦២៤ | ១១,៥៩៣ | ៤៧,២៤២ |
| ពន្ធពន្យារជាបំណុល | (៤,៦៥៣) | (១៨,៨២១) | - | - |
| | ៦,៣៧៩ | ២៥,៨០៣ | ១១,៥៩៣ | ៤៧,២៤២ |

## ១១.១ ពន្ធពន្យារជាទ្រព្យសកម្ម (ត)

(i) ការប្រែប្រួលពន្ធពន្យារជាទ្រព្យសកម្មក្នុងឆ្នាំមានដូចខាងក្រោម៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | ១១,៥៩៣ | ៤៧,២៤២ | ៦,៩៥០ | ២៧,៩២៥ |
| បម្រែបម្រួលក្នុងចំណេញ ឬខាត | (៥,២១៤) | (២១,២៥៦) | ៤,៦៤៣ | ១៨,៨១៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៨៣) | - | ៥០៤ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៦,៣៧៩ | ២៥,៨០៣ | ១១,៥៩៣ | ៤៧,២៤២ |

(ii) ពន្ធពន្យារជាទ្រព្យសកម្ម/(បំណុល) បានមកពីឯកតាដូចខាងក្រោម៖

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| រំលស់រហ័ស | ៨១២ | ៣,២៨៥ | ២,៨៨៦ | ១១,៧៦០ |
| ការខាតបង់លើសំវិធានធន | ១០,២២០ | ៤១,៣៤០ | ៣,៧៥២ | ១៥,២៨៩ |
| លម្អៀងលើអត្រាប្តូរប្រាក់ | (៤,៦៥៣) | (១៨,៨២២) | ៤,៩៥៥ | ២០,១៩៣ |
| | ៦,៣៧៩ | ២៥,៨០៣ | ១១,៥៩៣ | ៤៧,២៤២ |

## ១១.២ចំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | ២០២០ | | ២០១៩ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | ៤៨,២១៤ | ១៩៦,៤៧២ | ២៣,៤១៣ | ៩៤,០៧៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៧៤,០៩៩ | ៣០២,១០៣ | ៤៥,៥៤៧ | ១៨៤,៥៥៦ |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (៣៣,៧៧៨) | (១៣៧,៧១៣) | (២០,៧៤៦) | (៨៤,០៦៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២,៧៣៨) | - | ១,៩០៦ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៨៨,៥៣៥ | ៣៥៨,១២៤ | ៤៨,២១៤ | ១៩៦,៤៧២ |

## ១១.៣ចំណាយពន្ធលើប្រាក់ចំណេញ

អនុលោមទៅតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា ១% នៃប្រាក់ចំណូលសរុប នៅពេលដែលពន្ធមួយណាមានចំនួនច្រើនជាង។

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ពន្ធលើប្រាក់ចំណេញ | ៧៤,០៩៩ | ៣០២,១០៣ | ៤៥,៥៤៧ | ១៨៤,៥៥៦ |
| ពន្ធពន្យារ | ៥,២១៤ | ២១,២៥៦ | (៤,៦៤៣) | (១៨,៨១៣) |
| | ៧៩,៣១៣ | ៣២៣,៣៥៩ | ៤០,៩០៤ | ១៦៥,៧៤៣ |

### ១១.៣ចំណាយពន្ធលើប្រាក់ចំណេញ (ត)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលគណនាតាមអត្រាពន្ធជាផ្លូវការ ធៀបទៅនឹងពន្ធលើប្រាក់ចំណេញដែលបង្ហាញក្នុងចំណេញ ឬខាតមានដូចខាងក្រោមៈ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣០០,៤២៥ | ១,២២៤,៨៣២ | ១១១,៨៤៣ | ៤៥៣,១៨៧ |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធផ្លូវការ ២០% | ៦០,០៨៥ | ២៤៤,៩៦៦ | ២២,៣៦៩ | ៩០,៦៣៧ |
| ចំណាយមិនអាចកាត់កងបាន | ១៧៧ | ៧២២ | ៧៥៤ | ៣,០៥៥ |
| ផ្សេងៗ | ១៩,០៥១ | ៧៧,៦៧១ | ១៧,៧៨១ | ៧២,០៥១ |
| | ៧៩,៣១៣ | ៣២៣,៣៥៩ | ៤០,៩០៤ | ១៦៥,៧៤៣ |

ការគណនានៃការចំណាយពន្ធលើប្រាក់ចំណេញនេះ គឺជាប្រធានបទក្នុងការពិនិត្យ និងការវាយតម្លៃចុងក្រោយរបស់អាជ្ញាធរពន្ធ។

## ១២. ដើមទុន

| | ២០២០ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ចំនួន | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ចំនួន | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ចុះបញ្ជី និងបោះផ្សាយ ក្នុងតម្លៃ ១ ដុល្លារ ក្នុងមួយហ៊ុន | ២,៥៥៧,៧៦៥ | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ | ២,៥៥៧,៧៦៥ | ២,៥៥៧,៧៦៥ | ១០,២៣១,០៦០ |

## ១២. ដើមទុន (ត)

នៅថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០២០ ភាគទុនិកបានអនុម័តចំពោះការស្នើសុំលាលែងពីប្រធានក្រុមប្រឹក្សាភិបាល និងការលក់ភាគហ៊ុនរបស់លោក ឡាយ គឹមឆេន ទៅឲ្យភាគទុនិក ៤ ផ្សេងទៀត ដែលមានតម្លៃ ១ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។

រចនាសម្ព័ន្ធភាគហ៊ុននេះបានផ្លាស់ប្តូរដោយការផ្ទេរភាគហ៊ុនរបស់លោកឡាយ គឹមឆេន ចំនួន ៩៧១,៧០០ ទៅឲ្យភាគទុនិក ៤ ផ្សេងទៀតដូចខាងក្រោម។

| | ២០២០ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | **ភាគរយនៃ ភាគហ៊ុន កាន់កាប់** | **ចំនួន ភាគហ៊ុន** | **ចំនួន ដុល្លារអាមេរិក** | **ភាគរយនៃ ភាគហ៊ុន កាន់កាប់** | **ចំនួន ភាគហ៊ុន** | **ចំនួន ដុល្លារអាមេរិក** |
| លោក ឡាយ គឹមឆេន | - | - | - | ៣៨% | ៩៧១,៧០០ | ៩៧១,៧០០ |
| លោក ឈុន ស៊ីណា | ៦៤% | ១,៦៤១,៨៧៥ | ១,៦៤១,៨៧៥ | ១៣% | ៣៣៩,៨៨៧ | ៣៣៩,៨៨៧ |
| លោក ឈុន ស្រ៊ា | ២១% | ៥៤៨,១២២ | ៥៤៨,១២២ | ៤០% | ១,០១៨,១៤១ | ១,០១៨,១៤១ |
| អ្នកស្រី ឈុន វ៉ាន់ណុច | ៨% | ២០២,០៨៦ | ២០២,០៨៦ | ៥% | ១២៥,៣២១ | ១២៥,៣២១ |
| អ្នកស្រី ឈុន វ៉ាន់ណាល់ | ៦% | ១៦៥,៦៨២ | ១៦៥,៦៨២ | ៤% | ១០២,៧១៦ | ១០២,៧១៦ |
| | ១០០% | ២,៥៥៧,៧៦៥ | ២,៥៥៧,៧៦៥ | ១០០% | ២,៥៥៧,៧៦៥ | ២,៥៥៧,៧៦៥ |

នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០២០ ក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជាចំពោះការស្នើសុំថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០២០ សំរាប់ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុន។

លក្ខន្តិកៈនៃក្រុមហ៊ុនដែលត្រូវបានកែសំរួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរខាងលើ ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មកាលពីថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២១។

## ១៣. ទុនបម្រុងតាមបទប្បញ្ញត្តិ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ២.៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ២.៤) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ (*) | - | - | ២០,៦៨៨ | ៨៤,៣០៤ |

## ១៣. ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

(*) បម្រែបម្រួលទុនបម្រុងតាមបទប្បញ្ញត្តិ៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | ២០,៦៨៨ | ៨៤,៣០៤ | - | - |
| ការផ្ទេរ | (២០,៦៨៨) | (៨៤,៣៤៥) | ២០,៦៨៨ | ៨៣,៨២៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤១ | - | ៤៧៦ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | - | - | ២០,៦៨៨ | ៨៤,៣០៤ |

ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុង ត្រូវបានធ្វើឡើងនៅពេលដែលសំវិធានធនតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ខ្ពស់ជាងសំវិធានធនតាម CIFRS for SMEs៖

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| សំវិធានធនលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា | | | | |
| - ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ២៤,០៤៩ | ៩៨,០៤៨ | ២០,១៥៤ | ៨២,១២៨ |
| - ឥណទានផ្តល់ដល់អតិថិជន | ៩១,២៦១ | ៣៧២,០៧១ | ២២,៥១៦ | ៩១,៧៥៣ |
| | ១១៥,៣១០ | ៤៧០,១១៩ | ៤២,៦៧០ | ១៧៣,៨៨១ |
| សំវិធានធនលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុតាម CIFRS for SMEs (កំណត់សម្គាល់ ៧) | ១១៩,០៩១ | ៤៨១,៧២៣ | ២១,៩៨២ | ៨៩,៥៧៧ |
| | - | - | ២០,៦៨៨ | ៨៤,៣០៤ |

## ១៤. ចំណូលពីការប្រាក់

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ឥណទានផ្តល់ដល់អតិថិជន | ២៦៧,២៦៩ | ១,០៨៩,៦៥៦ | ៣០៥,២៦៨ | ១,២៣៦,៩៤៦ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧៨៥ | ៣,២០០ | ១,៦៩៤ | ៦,៨៦៤ |
| | ២៦៨,០៥៤ | ១,០៩២,៨៥៦ | ៣០៦,៩៦២ | ១,២៤៣,៨១០ |

## ១៥. ចំណាយទូទៅ និងរដ្ឋបាល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ប្រាក់បៀវត្សន៍ និងចំណាយពាក់ព័ន្ធ | ៩០៦,៩២៩ | ៣,៦៩៧,៥៥០ | ១,៣២៥,៤៧៥ | ៥,៣៧០,៨២៥ |
| ចំណាយលើការជួល | ២២៨,៩២៦ | ៩៣៣,៣៣១ | ២៤៦,១១៥ | ៩៩៧,២៥៨ |
| ចំណាយការដឹកជញ្ជូន និងយានយន្ត | ៤៤,៥៣៧ | ១៨១,៥៧៧ | ៤២,០៩២ | ១៧០,៥៥៧ |
| ថ្លៃទឹក និងថ្លៃភ្លើង | ៣០,២២៤ | ១២៣,២២៣ | ៣០,០២៣ | ១២១,៦៥៣ |
| ចំណាយវិជ្ជាជីវៈ និងនីតិកម្ម | ៣០,០៧២ | ១២២,៦០៤ | ៩៥,៣១៧ | ៣៨៦,២២៤ |
| ចំណាយលើការទំនាក់ទំនង | ២៩,៧៤៧ | ១២១,២៧៩ | ៣៧,០០៩ | ១៤៩,៩៦០ |
| ចំណាយលើសំភារៈការិយាល័យ | ៥,៨៦៨ | ២៣,៩២៤ | ៤,៦០៤ | ១៨,៦៥៥ |
| ចំណាយលើទីផ្សារ និងការផ្សព្វផ្សាយ | ៤,១៩៧ | ១៧,១១១ | ២,៨៥១ | ១១,៥៥២ |
| ចំណាយលើការធ្វើដំណើរ | ១,៨៨៧ | ៧,៦៩៣ | ២៥,០៤៥ | ១០១,៤៨២ |
| ចំណាយលើការជួសជុល | ១,៨៥០ | ៧,៥៤២ | ៣,៦២៦ | ១៤,៦៩៣ |
| ចំណាយពីការលុបទ្រព្យ និងបរិក្ខារ | ១៧២ | ៧០១ | ២,៥៥០ | ១០,៣៣៣ |
| ចំណាយផ្សេងៗ | ៥,២០៣ | ២១,២១៣ | ៤៩,៣៨៩ | ២០០,១២៥ |
| | ១,២៨៩,៦១២ | ៥,២៥៧,៧៤៨ | ១,៨៦៤,០៩៦ | ៧,៥៥៣,៣១៧ |

## ១៦. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់ ៤) | ៤៨,០៥៩ | ១៩៤,៣៩៩ | ៦០,០៣៣ | ២៤៤,៦៣៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា (កំណត់សម្គាល់ ៥) | ១០,៣០៦ | ៤១,៦៨៨ | ៩,៥៤១ | ៣៨,៨៧៩ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ (ជាមួយរយៈពេលកំណត់ ឬស្មើ ៣ ខែ) (កំណត់សម្គាល់ ៦) | ២,៤០៤,៨៥៣ | ៩,៧២៧,៦៣០ | ២,០១៥,៣៥៤ | ៨,២១២,៥៦៨ |
| | ២,៤៦៣,២១៨ | ៩,៩៦៣,៧១៧ | ២,០៨៤,៩២៨ | ៨,៤៩៦,០៨១ |

## ១៧. ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| ថ្លៃជួលការិយាល័យ | ៩៣,៣៣៣ | ៣៨០,៥១៩ | ១១៨,០០០ | ៤៧៨,១៣៦ |
| ចំណាយសម្រាប់នាយក និងអ្នកគ្រប់គ្រងសំខាន់ៗ | ៤៨,៦៤៩ | ១៩៨,៣៤២ | ៤៦,២៧៤ | ១៨៧,៥០២ |

## ១៨. ភតិសន្យាជួល

ក្រុមហ៊ុន មានភតិសន្យាលើការជួលការិយាល័យជាមួយការសន្យាជួលអប្បបរមាដូចខាងក្រោមៈ

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| តិចជាង ១ ឆ្នាំ | ១៧១,២០០ | ៦៩២,៥០៤ | ២២១,៩០៣ | ៩០៤,២៥៥ |
| ចាប់ពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ | ១៧៧,៥៥០ | ៧១៨,១៩០ | ៧២៤,២៥៥ | ២,៩៥១,៣៣៩ |
| ចាប់ពី ៥ ឆ្នាំ | - | - | ៧៩,៨៣៦ | ៣២៥,៣៣២ |
| | ៣៤៨,៧៥០ | ១,៤១០,៦៩៤ | ១,០២៥,៩៩៤ | ៤,១៨០,៩២៦ |

## ១៩. ពន្ធជាយថាហេតុ

ពន្ធស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយអាជ្ញាធរដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងការគិតការប្រាក់។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទប្រឈមនឹងការបកស្រាយផ្សេងៗគ្នា។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានការបកស្រាយខុសៗគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។

## ២០. ព្រឹត្តិការណ៍សារវន្ត

*ផលប៉ះពាល់នៃការផ្ទុះឡើងនៃណូវែលវីរុសកូរ៉ូណាដល់ក្រុមហ៊ុន*

ចាប់តាំងពីខែ មករា ឆ្នាំ ២០២០ ការផ្ទុះឡើងនៃ Coronavirus ("COVID-១៩") មានផលប៉ះពាល់ដល់ស្ថានភាពពាណិជ្ជកម្មជាសាកល និងប្រទេសកម្ពុជា។ក្រុមហ៊ុននឹងបន្តការយកចិត្តទុកដាក់ទៅលើស្ថានភាពនៃ COVID-១៩ និងឆ្លើយតបយ៉ាងសកម្មចំពោះផលប៉ះពាល់របស់វាទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន។

## ២១. គោលនយោបាយគណនេយ្យសំខាន់ៗ

### ២១.១មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងសាខារបស់ខ្លួន។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាទាំងអស់ត្រូវបានលុបបំបាត់ចោល។

## ២១.២សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ និងប្រាក់បញ្ញើនៅធនាគារ ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លី ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២១.៣ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២១.៤ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ដែលរួមបញ្ចូលទាំងប្រាក់តម្កល់ធានាដើមទុនត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ប្រាក់តម្កល់ធានាដើមទុន ត្រូវបានរក្សាទុកស្របតាមច្បាប់កម្ពុជាស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុហើយត្រូវបានកំណត់ដោយភាគរយនៃដើមទុនអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់ធានាដើមទុនមិនអាចផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ហេតុដូច្នេះមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសមមូលសាច់ប្រាក់សម្រាប់បង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

## ២១.៥ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិសន្ទស្សដែលការទូទាត់មានលក្ខណៈថេរ ឬអាចកំណត់បានដែលមិនមានសម្រង់តម្លៃក្នុងទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬក្នុងរយៈពេលខ្លីណាមួយនោះទេ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានគណនាតាមតម្លៃសមស្រប បូកនឹងការចំណាយប្រតិបត្តិការផ្ទាល់ ហើយត្រូវបានគណនាជាបន្តបន្ទាប់គិតតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## ២១.៦ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២១.៧ទ្រព្យ និងបរិក្ខារ

### (ក) *ការទទួលស្គាល់ និងការវាស់វែង*

ផ្នែកទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមវិធីសាស្ត្រថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។

នៅពេលផ្នែកនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នាធាតុទាំងនោះត្រូវបានគេចាត់ទុកជាផ្នែកផ្សេងៗ (សមាសធាតុចម្បងៗ)នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតលើការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញផ្សេងៗនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### (ខ) *ការចំណាយបន្ទាប់*

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន ហើយតម្លៃរបស់វាអាចវាស់វែងបានដោយភាពជឿជាក់។ តម្លៃយោងនៃធាតុដែលបានជំនួសនោះត្រូវបានលុបចោល។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

### (គ) *រំលស់*

រំលស់ ត្រូវបានគណនា និងបែងចែកថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃដែលនៅសល់ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗ។ រំលស់ចាប់ផ្តើមគណនានៅពេលដែលទ្រព្យសកម្មអាចប្រើប្រាស់បាន។ ចំពោះវិធីសាស្ត្ររំលស់ និងអាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារមានដូចខាងក្រោម៖

| | | |
|---|---|---|
| ការកែលំអអាគារជួល | ២០ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ៤ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ថយចុះ |
| បរិក្ខារកុំព្យូទ័រ | ២ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ថយចុះ |
| បរិក្ខារការិយាល័យ និងបរិក្ខារផ្សេងៗ | ៤ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ថយចុះ |
| យានយន្ត | ៤ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ថយចុះ |

ប្រសិនបើមានការកែប្រែជាសារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ តម្លៃនៅសល់នៃទ្រព្យ និងបរិក្ខារនោះ រំលស់ត្រូវបានកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

ទ្រព្យ និងបរិក្ខារដែលបានធ្វើរំលស់អស់ គឺត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់លក់ចេញ ឬលុបចោល។

## ២១.៨ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងថ្លៃដើមដែលជាប់ទាក់ទង ត្រូវបានកំណត់ដោយតម្លៃដើម ដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។

ទ្រព្យសកម្មអរូបី ត្រូវបានរំលស់ផ្អែកលើវិធីសាស្ត្ររំលស់ថេរក្នុងរយៈពេល ១០ ឆ្នាំ។ ប្រសិនបើមានកែប្រែជាសារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់នៃទ្រព្យសកម្មអរូបីនោះ ត្រូវបានកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

## ២១.៩ឱនភាពនៃតម្លៃ

### ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញានោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយលើការលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់លំហូរសាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមទៅក្នុងក្រុមទ្រព្យសកម្មតូចៗបំផុត ដែលអាចបង្កើតជាលំហូរសាច់ប្រាក់ពីការប្រើប្រាស់ ដោយមិនពឹងផ្អែកលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលបានមកវិញ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាជាចំណេញ ឬខាត។

## ២១.១០បំណុលផ្សេងៗ

បំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២១.១១សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល នាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយចំនួនសំវិធានធន ត្រូវបានប៉ាន់ស្មានប្រកបដោយភាពជឿជាក់។ សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគតដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

## ២១.១២អត្ថប្រយោជន៍និយោជិត

### *(ក) អត្ថប្រយោជន៍របស់និយោជិករយៈពេលខ្លី*

អត្ថប្រយោជន៍របស់បុគ្គលិករយៈពេលខ្លីជាចំណាយ នៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ជូន។ បំណុលត្រូវបានទទួលស្គាល់ចំពោះចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ប្រសិនបើក្រុមហ៊ុនមាន កាតព្វកិច្ចតាមច្បាប់ ឬប្រយោលដើម្បីបង់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្មកន្លងមកដែលផ្តល់ដោយបុគ្គលិក ហើយកាតព្វកិច្ចអាចត្រូវបានប៉ាន់ប្រមាណបានដោយភាពជឿជាក់។

### *(ខ) អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ*

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារមុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្តពីនិយោជិត ដែលលើសពីតម្រូវការអត្ថប្រយោជន៍នោះ ត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលតាមការស្នើសុំនេះ។

នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារ លើសពី ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាទីផ្សារនៅចុងការិយបរិច្ឆេទ។

### *(គ) អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ*

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង ដែលរួមមានប្រាក់អតីតភាពការងារ គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបានក្នុងការបំពេញការងារក្នុងការិយបរិច្ឆេទមុន និងបច្ចុប្បន្ន។ អត្ថប្រយោជន៍និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។

## ២១.១៣ភាគលាភ

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន មុនពេលចុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់ថាជាបំណុល និងត្រូវបានកាត់ចេញពីប្រាក់ចំណេញរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុនបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍មិនត្រូវបានទទួលស្គាល់ថាជាបំណុលទេ ប៉ុន្តែត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ២១.១៤ការប្រាក់

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ អត្រាការប្រាក់ប្រសិទ្ធិភាព គឺជាអត្រាដែលធ្វើអប្បហារសាច់ប្រាក់ ដែលរំពឹងថាត្រូវទូទាត់ ឬទទួលបានពេលអនាគតតាមរយៈអាយុកាលដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬក្នុងករណីរយៈពេលខ្លីសមស្របមួយ) ឲ្យមកស្មើនឹងតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនត្រូវប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែនការបាត់បង់ឥណទាននាពេលអនាគតទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធិភាពរួមមានថ្លៃប្រតិបត្តិការ និងកម្រៃ និងពិន្ទុដែលបានបង់ ឬទទួលដែលជាផ្នែកភ្ជាប់នឹងអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការ រួមមានការចំណាយបន្ថែមដែលកើតឡើងដោយផ្ទាល់ទៅនឹងការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## ២១.១៥កម្រៃជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលភ្ជាប់នឹងអត្រាការប្រាក់ប្រសិទ្ធិភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានបញ្ចូលក្នុងការគណនាអត្រាការប្រាក់ប្រសិទ្ធិភាព។

ចំណូលកម្រៃ និងជើងសារផ្សេងៗ ត្រូវបានទទួលស្គាល់នៅពេលសេវាកម្មពាក់ព័ន្ធត្រូវបានបំពេញ។ ប្រសិនបើកិច្ចសន្យាឥណទានមិនរំពឹងថានឹងមានការដកប្រាក់កម្ចី នោះថ្លៃសេវាដែលទាក់ទងនឹងប្រាក់កម្ចី ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានថេរក្នុងរយៈពេលនៃកិច្ចសន្យាឥណទាន។

កម្រៃចំណាយ និងជើងសារផ្សេងៗ ពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ និងថ្លៃសេវាកម្ម ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មបានទទួល។

## ២១.១៦ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌនៃភតិសន្យានោះ ផ្ទេរជាសារវន្តនូវរាល់ហានិភ័យ សិទ្ធិអាស្រ័យផល និងកម្មសិទ្ធិនៃទ្រព្យសកម្ម ភតិសន្យាដល់ក្រុមហ៊ុន។ ភតិសន្យាផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

សិទ្ធិទៅលើទ្រព្យសកម្មក្រោមភតិសន្យាហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរបស់ក្រុមហ៊ុនតាមតម្លៃសមស្រប ឬប្រសិនបើទាបជាងត្រូវយកតម្លៃបច្ចុប្បន្ននៃការទូទាត់អប្បបរមាលើភតិសន្យា) នៅពេលចាប់ផ្តើមនៃភតិសន្យា។ បំណុលពាក់ព័ន្ធដែលត្រូវទូទាត់សងទៅឲ្យភតិបតី ត្រូវបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាបំណុលភតិសន្យាហិរញ្ញវត្ថុ។ ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងចំណាយហិរញ្ញប្បទាន និងការកាត់បន្ថយបំណុលភតិសន្យាដើម្បីទទួលបាននូវអត្រាការប្រាក់ថេរមួយលើសមតុល្យបំណុលដែលនៅសល់។ ចំណាយហិរញ្ញប្បទានត្រូវបានដកចេញនៅពេលធ្វើការវាស់វែងជាចំណេញ ឬខាត។ ទ្រព្យសកម្មក្រោមភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលក្នុងទ្រព្យ និងបរិក្ខារ ហើយត្រូវធ្វើរំលស់ និងប៉ាន់ប្រមាណឱនភាពនៃតម្លៃដូចគ្នាទៅនឹងទ្រព្យសកម្មផ្សេងទៀតរបស់ក្រុមហ៊ុនផងដែរ។

ថ្លៃឈ្នួលដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការត្រូវបានកត់ត្រាជាចំណេញ ឬខាតតាមមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា។

## ២១.១៧ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត លើកលែងតែធាតុណាដែលបានទទួលស្គាល់ក្នុងរបាយការណ៍ លទ្ធផលលម្អិតផ្សេងទៀត។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារត្រូវបានកំណត់ទៅលើភាពលំអៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ (ហៅថាភាពលំអៀងបណ្តោះអាសន្ន)។

ពន្ធពន្យារជាបំណុល ត្រូវទទួលស្គាល់លើភាពលម្អៀងបណ្តោះអាសន្នដែលរំពឹងថា នឹងបង្កើនប្រាក់ចំណេញដែលជាប់ពន្ធនាពេលអនាគត។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់សម្រាប់ភាពលំអៀងបណ្តោះអាសន្នទាំងឡាយណាដែលរំពឹងថានឹង កាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតរួមទាំងការខាតពន្ធ ឬឥណទានពន្ធដែលមិនទាន់បានប្រើប្រាស់ផ្សេងៗ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តាមចំនួនដែលគិតថាអាចប្រើប្រាស់បានខ្ពស់បំផុត ដោយផ្អែកលើមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធនាពេលបច្ចុប្បន្ន ឬនាពេលអនាគត ហើយមានលទ្ធភាពខ្ពស់ក្នុងការអាចយកមកប្រើប្រាស់បាន។

តម្លៃយោងសុទ្ធនៃពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានធ្វើនិយ័តភាពដើម្បី ឆ្លុះបញ្ចាំងពីការវាយតម្លៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ និយ័តភាពទាំងនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិតលើកលែងតែនិយ័តភាពដែលពាក់ព័ន្ធនឹងខ្ទង់ចំណូល ឬចំណាយដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗដោយនិយ័តភាពនោះត្រូវតែទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ពន្ធពន្យារ ត្រូវបានគណនាតាមអត្រាពន្ធដែលប្រើសម្រាប់ការគណនាប្រាក់ចំណេញជាប់ពន្ធ (ការខាតពន្ធ) ក្នុងការិយបរិច្ឆេទដែលពន្ធពន្យារជាទ្រព្យសកម្មរំពឹងថានឹងប្រើប្រាស់បាន ឬបំណុលជាពន្ធពន្យាររំពឹងថានឹងត្រូវទូទាត់ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍នានៅសម្រាប់កាលបរិច្ឆេទរាយការណ៍។

## ២១.១៨ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(ក)* ***ការទទួលស្គាល់***

ក្រុមហ៊ុន ទទួលស្គាល់ដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនបានក្លាយជាភាគីនៃការផ្តល់កិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលរួមចំណែកដោយផ្ទាល់ទៅលើការទិញ ឬលក់ឧបករណ៍នោះ។

## ២១.១៨ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

### *(ខ) ចំណាត់ថ្នាក់*

ក្រុមហ៊ុនចាត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ខ្លួនជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ដែលមានចែងក្នុងផ្នែកទី ១១ ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន។

### *(គ) ការឈប់ទទួលស្គាល់*

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្ម ហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ឬក្នុងករណីមិនផ្ទេរចេញ ឬមិនរក្សាហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុ និងមិនរក្សាការគ្រប់គ្រងទៅលើទ្រព្យសកម្មដែលផ្ទេរចេញ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលកាតព្វកិច្ចកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

### *(ឃ) ការកាត់កង*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃយោងសុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានតម្លៃសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលជាប្រចាំ។

### *(ង) ការវាស់វែងរំលស់ថ្លៃដើម*

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលបានកត់ត្រាតាមប្រាក់ដើមដំបូង ដកការទូទាត់ប្រាក់ដើម បូក ឬដកចំនួនរំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងចំនួនដល់កាលកំណត់ ដកឱនភាពនៃតម្លៃ។

### *(ច) ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលគួរទទួលបានដើម្បីលក់ទ្រព្យសកម្ម ឬបង់ដើម្បីផ្ទេរបំណុល ក្នុងប្រតិបត្តិការរៀបរយ រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទវាស់វែងជាគោល ឬក្នុងករណីមិនមាន ត្រូវយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុតដែលក្រុមហ៊ុនទទួលបាននៅកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលការឆ្លុះបញ្ចាំងពីហានិភ័យមិនដំណើរការរបស់វានោះទេ។

ប្រសិនបើអាចក្រុមហ៊ុនវាស់វែងតម្លៃសមស្រប ដោយប្រើប្រាស់តម្លៃប៉ាន់ស្មានដែលបានដកស្រង់ពីទីផ្សារសកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុនោះ។ ទីផ្សារត្រូវបានចាត់ទុកថាសកម្មប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលត្រូវកើតឡើងដោយមានបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃជាប្រចាំ។

## ២១.១៨ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ច) ការវាស់វែងតម្លៃសមស្រប (ត)*

ប្រសិនបើមិនមានតម្លៃប៉ាន់ស្មានពីទីផ្សារសកម្មទេនោះ ក្រុមហ៊ុនអាចប្រើបច្ចេកទេសវាយតម្លៃដែលប្រើប្រាស់ធាតុចូលដែលអាចសង្កេតបានជាអតិបរមា និងកាត់បន្ថយការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបានជាអតិបរមា។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ដំបូងជាធម្មតា គឺជាតម្លៃប្រតិបត្តិការធម្មតា ឧទាហរណ៍ តម្លៃសមស្របនៃតម្លៃតបស្នងដែលបានផ្តល់ឲ្យ ឬទទួលបាន។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របនៅពេលទទួលស្គាល់ដំបូង ខុសគ្នាពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របមិនមានការបញ្ជាក់ពីសម្រង់តម្លៃពីទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃ ដែលប្រើប្រាស់ទិន្នន័យពីទីផ្សារដែលអាចសង្កេតបាន នោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដោយនិយតកម្មដើម្បីពន្យារភាពខុសគ្នារវាងតម្លៃសមស្របនៃការទទួលស្គាល់ដំបូង និងតម្លៃ ប្រតិបត្តិការ។ បន្ទាប់មកភាពខុសគ្នានោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋាន សមស្របទៅតាមអាយុកាលឧបករណ៍ ប៉ុន្តែមិនយូរជាងពេលដែលធ្វើការវាយតម្លៃ គឺត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចសង្កេតបាន ឬប្រតិបត្តិការត្រូវបានបិទ។

*(ឆ) ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព*

**ភស្តុតាងដែលបញ្ជាក់ពីឱនភាព**

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយថ្លៃដើម ឬរំលស់ថ្លៃដើមមានសញ្ញាណឱនភាពឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៅពេលមានភស្តុតាងបង្ហាញថាព្រឹត្តិការណ៍ខាតបង់បានកើតឡើង បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ហើយព្រឹត្តិការណ៍បាត់បង់មានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់ នាពេលអនាគតនៃទ្រព្យសកម្មដែលអាចប៉ាន់ស្មានបាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មមានឱនភាព រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ភាពយឺតយ៉ាវ ឬការមិនទូទាត់សងដោយអ្នកខ្ចី
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុលនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់នៃទីផ្សារសកម្មសម្រាប់មូលប័ត្រ ឬ
- ទិន្នន័យ ដែលអាចសង្កេតបានទាក់ទងទៅនឹងក្រុមនៃទ្រព្យសកម្មដូចជាការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពទូទាត់របស់កូនបំណុល ឬអ្នកបោះផ្សាយនៅក្នុងក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងគ្នានៅក្នុងក្រុម។

## ២១.១៨ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ឆ)* ***ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព (ត)***

**ការវាយតម្លៃទោល និងជាក្រុម**

រាល់ទ្រព្យសកម្មទោលសារវន្ត ត្រូវបានវាយតម្លៃផ្សេងៗពីគ្នាចំពោះឱនភាព។

ទ្រព្យសកម្មដែលត្រូវបានគេរកឃើញថា មិនមានឱនភាពត្រូវបានវាយតម្លៃជាក្រុមលើឱនភាពដែលបានកើតឡើង ប៉ុន្តែមិនទាន់បានកំណត់បញ្ជាក់នៅឡើយ។

សមាសធាតុនីមួយៗនៃសំវិធានធនលើឱនភាព ត្រូវអនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាយតម្លៃទោលចំពោះឱនភាព ហើយត្រូវបានគេរកឃើញថាមានឱនភាព ហើយផ្អែកលើការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រងលើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃដែលអាចកំណត់បាននៃទ្រព្យបញ្ចាំណាមួយ។ ឱនភាពនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃលើគុណប្រយោជន៍របស់វា ហើយយុទ្ធសាស្ត្រ និងការប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលអាចរកបានមកវិញត្រូវបានអនុម័តដោយអ្នកគ្រប់គ្រងដោយឯករាជ្យ។

សមាសធាតុជាក្រុមនៃសំវិធានធន ត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃប្រាក់កម្ចីមានលក្ខណៈដូចគ្នាដែលមិនត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្តទោល និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈសារវន្តទោល ប៉ុន្តែមិនត្រូវបានគេរកឃើញថាមានឱនភាព

សំវិធានធនជាក្រុមនៃប្រាក់កម្ចីដែលមានលក្ខណៈដូចគ្នាត្រូវបាន បង្កើតឡើងដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាបន្ត ឬសម្រាប់បណ្តាំឥណទានតូចៗ ដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬរូបមន្តផ្អែកលើបទពិសោធន៍ អត្រាការខាតបង់យោងតាមនិន្នាការពីមុន។

ក្នុងការវាយតម្លៃសំវិធានធនលើឱនភាពជាក្រុម គណៈគ្រប់គ្រងពិចារណាលើកត្តាដូចជា គុណភាពឥណទាន ទំហំឥណទាន ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ច។ ដើម្បីប៉ាន់ប្រមាណនូវសំវិធានធនចាំបាច់ ការប៉ាន់ស្មានត្រូវបានបង្កើតឡើងដើម្បីកំណត់ពីរបៀបការខាតបង់ជាយថាផល ត្រូវបានកំណត់ និងតម្រូវបញ្ចូលប៉ារ៉ាម៉ែត្រ ដែលផ្អែកលើបទពិសោធន៍ពីមុន និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធនអាស្រ័យលើការសន្មត់ម៉ូដែល និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនរួម។

**ការវាស់វែង**

សំវិធានធនលើឱនភាពនៃតម្លៃនៃទ្រព្យសកម្ម វាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនាជាភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលត្រូវបានកាត់បន្ថយតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្មនោះ។

## ២១.១៨ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ឆ) ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព (ត)*

**តំហយនៃឱនភាព និងការលុបចោល**

ប្រសិនបើក្នុងរយៈពេលជាបន្តបន្ទាប់ចំនួននៃតម្លៃឱនភាពមានការថយចុះ ហើយការថយចុះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវដកចេញការខាតបង់នៃឱនភាពដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយនិយ័តភាពគណនីសំវិធានធន។

តំហយសំវិធានធន មិនអាចលើសពីតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ដកសំវិធានធន) ដែលលើសពីចំនួនតម្លៃយោងដែលឱនភាពតម្លៃមិនត្រូវបានទទួលស្គាល់ពីមុន។ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួនទឹកប្រាក់កែតម្រូវនៅក្នុងចំណេញ ឬខាត។

ក្រុមហ៊ុនលុបចោលបំណុល ឬបំណុលវិនិយោគមួយផ្នែកខ្លះ ឬទាំងអស់ដែលពាក់ព័ន្ធនឹងសំវិធានធនលើឱនភាពតម្លៃ នៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពមិនអាចប្រមូលមកវិញ។

## ២១.១៩ទុនបម្រុងតាមបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីប្រកាសលេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន និងសារាចរលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីការអនុវត្តប្រកាសស្តីពីការផ្តល់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ដែលតម្រូវ អោយគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងអស់ អនុវត្តការវាស់វែង ការធ្វើសំវិធានធនឥណទាន ដោយផ្អែកតាមអត្រាហានិភ័យឥណទានដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---:|---:|
| ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ) | | |
| ស្តង់ដារ | ពី ០ ទៅ ១៤ ថ្ងៃ | ១% |
| ឃ្លាំមើល | ពី ១៥ ទៅ ២៩ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៣០ ទៅ ៥៩ ថ្ងៃ | ២០% |
| ជាប់សង្ស័យ | ពី ៦០ ទៅ ៨៩ ថ្ងៃ | ៥០% |
| បាត់បង់ | ៩០ ថ្ងៃ ឬច្រើនជាង | ១០០% |

## ២១.១៩ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ) | | |
| ស្តង់ដារ | ពី ០ ទៅ ២៩ ថ្ងៃ | ១% |
| ឃ្លាំមើល | ពី ៣០ ទៅ ៨៩ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៩០ ទៅ ១៧៩ ថ្ងៃ | ២០% |
| ជាប់សង្ស័យ | ពី ១៨០ ទៅ ៣៥៩ ថ្ងៃ | ៥០% |
| បាត់បង់ | ៣៦០ ថ្ងៃ ឬច្រើនជាង | ១០០% |

យោងតាមមាត្រាទី ៧៣ ក្រុមហ៊ុនត្រូវតែធ្វើការប្រៀបធៀបសំវិធានធនគណនាស្របតាមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា និងសំវិធានធនគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និងមធ្យមៈ

(ក) ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិទាបជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ខ) ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិធំជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញរក្សាទុកទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិក្នុងគណនីមូលធន។

## ២១.២០សម្ព័ន្ធញាតិ

សហគ្រាស និងបុគ្គលដែលទាក់ទងផ្ទាល់ ឬមិនផ្ទាល់តាមរយៈអន្តរការីមួយឬច្រើន ឬត្រូវបានគ្រប់គ្រង ក្រោមការគ្រប់គ្រងរួមជាមួយក្រុមហ៊ុន រួមទាំងក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ និងក្រុមហ៊ុនសម្ព័ន្ធផ្សេងទៀតដែលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន សមាគម និងបុគ្គលដែលកាន់កាប់ដោយផ្ទាល់ ឬប្រយោលលើសិទ្ធបោះឆ្នោតរបស់ក្រុមហ៊ុន ដែលផ្តល់ឱ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់មកលើសហគ្រាស គណៈគ្រប់គ្រងសំខាន់ៗរួមមាននាយក និងបុគ្គលិកក្រុមហ៊ុន និងសមាជិកជិតស្និទ្ធជាមួយក្រុមគ្រួសាររបស់បុគ្គលនោះ ក៏ដូចជាក្រុមហ៊ុនដែលសហការជាមួយបុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធផងដែរ។

# ២២. តួលេខប្រៀបធៀប

ក្នុងអំឡុងពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០២០ អ្នកគ្រប់គ្រងបានរកឃើញការបង្ហាញខុស ដូចខាងក្រោមៈ

(ក). កម្រៃឥណទានមិនទាន់ទទួលស្គាល់ ត្រូវបានទទួលស្គាល់ជាការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ជាជាងកាត់បន្ថយពីឥណទានផ្តល់ដល់អតិថិជន។

(ខ). ការទទួលស្គាល់លើស នៃពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

## ២២. តួលេខប្រៀបធៀប (ត)

អ្នកគ្រប់គ្រង បានកំណត់ឡើងវិញតួលេខប្រៀបធៀបនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ដូចខាងក្រោម៖

| | ២០១៩ | | | |
|---|---|---|---|---|
| | កំណត់ឡើងវិញ | | តួលេខពីមុន | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| **ទ្រព្យសកម្ម** | | | | |
| ឥណទានផ្តល់ដល់អតិថិជន | ១,៦០៧,៧៥៩ | ៦,៥៥១,៦១៨ | ១,៥៨៧,៦០៦ | ៦,៤៦៩,៤៩៤ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១១,៥៩៣ | ៤៧,២៤២ | ៥១,២៩៩ | ២០៩,០៤៤ |
| **បំណុល** | | | | |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ៤៨,២១៤ | ១៩៦,៤៧២ | ៨៧,៩២១ | ៣៥៨,២៧៨ |
| **មូលធន** | | | | |
| ប្រាក់ចំណេញរក្សាទុក | ១,១៩០,៧៦២ | ៤,៨១៦,៩៨២ | ១,១៩១,២៩៧ | ៤,៨១៩,១៥០ |
| **របាយការណ៍លទ្ធផលលម្អិត** | | | | |
| ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | (២១,៩៨២) | (៨៩,០៧១) | (៤៦,៩៤០) | (១៩០,២០១) |

អគារលេខៈ ២១-២៣-២៥, ផ្លូវលេខ៥៩៨, សង្កាត់ភ្នំពេញថ្មី, ខណ្ឌ សែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា,
ទូរស័ព្ទលេខៈ០៨៦ ៦៥៥ ៩៩៩, វេបសាយ : www.niron.com.kh

Head Office: #២១-២៣-២៥, St.៥៩៨, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia.

Tel: ០៨៦ ៦៥៥ ៩៩៩, Website : www.niron.com.kh

E-mail: info@niron.com.kh, Website: www.niron.com.kh